ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ចម្លើយទៅនឹងសំណួរ

# បន្ថែមរបស់អង្គការសហប្រជាជាតិ

# លើរបាយការណ៍ជាតិ ស្តីពីការអនុវត្តន៍អនុសញ្ញាលុប បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនៅប្រទេសកម្ពុជា

កែសម្រួលតាមស្មារតីអង្គប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី

# ចម្លើយទៅនឹងសំណួរបន្ថែមរបស់អង្គការសហប្រជាជាតិ លើរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់ រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ នៅប្រទេសកម្ពុជា

( ឯកសារនេះបានកែសម្រួលតាមស្មារតីអង្គប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី)

## បញ្ហា និងសំណួរទូទៅ

**សំណួរទី១ : សូមរៀបរាប់អំពីដំណើរការរៀបចំរបាយការណ៍លើកដំបូង លើកទី២ និងលើកទី៣នេះ ហើយជាពិសេសសូមរៀបរាប់អំពីតួនាទីរបស់គណៈកម្មការសិទ្ធិមនុស្សនៅកម្ពុជា និងថាតើមានការដំណើរការការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសូមរៀបរាប់ថាតើរបាយការណ៍នេះត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដាក់ជូនទៅរដ្ឋសភាជាតិទេ?**

**ចម្លើយ :**

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ តាមព្រះរាជក្រឹត្យ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ដោយមាន :

**- សម្តេច ព្រះរាជអគ្គមហេសី ជាព្រះប្រធានកិត្តិយស**

- សម្តេចនាយករដ្ឋមន្ត្រី ជាអនុប្រធានកិត្តិយស

- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាប្រធាន

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានភារកិច្ចត្រូវរៀបចំរបាយការណ៍ ស្តីពីការអនុវត្ត CEDAW ជូនទៅអង្គការសហប្រជាជាតិ ។

ដើម្បីរៀបចំរបាយការណ៍នេះ ក្រុមប្រឹក្សាជាតិបានបង្កើតក្រុមការងារដែលមានសមាសភាពចម្រុះក្រសួង រួមមាន តំណាងក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសង្គម-កិច្ច ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារី ។

ក្នុងដំណើរការរៀបចំរបាយការណ៍ បានការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដោយបានផ្តល់អ្នកពិគ្រោះយោបល់មកជួយដឹកនាំ និងណែនាំដល់ក្រុមការងារផ្ទាល់ ។ សេចក្តីព្រាងរបាយការណ៍នេះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៣ ។

សេចក្តីព្រាងរបាយការណ៍នេះ បានដាក់ឆ្លងយោបល់ពីសង្គមស៊ីវិល ដែលមានអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងស្ត្រីចូលរួមក្នុងសិក្ខាសាលាដើម្បីផ្តល់យោបល់ ។

បន្ទាប់មកសេចក្ដីព្រាងរបាយការណ៍នេះ ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេចនាថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៣ ។

ក្រោយពីទទួលបានការសម្រេចឯកភាពពីគណៈរដ្ឋមន្ត្រីរួចហើយ ទើបធ្វើការបកប្រែសម្រួលជាភាសា-អង់គ្លេស ហើយបញ្ជូនមកអង្គការសហប្រជាជាតិ ។ របាយការណ៍នេះ ពុំបានដាក់ជូនទៅរដ្ឋសភាទេ ពីព្រោះតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនតម្រូវឱ្យឆ្លងរដ្ឋសភាឡើយ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) ជាស្ថាប័នសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល មានតួនាទី :

- ការពារលើកស្ទួយអភិវឌ្ឍន៍សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និង ពាក្យបណ្ដឹងតវ៉ានានា ។

- អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈ និង តាមមុខសញ្ញានីមួយៗ ។

- ផ្ដល់យោបល់ និងលើកសំណើជូនរាជរដ្ឋាភិបាល អំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអ និង ធ្វើយ៉ាងណាឱ្យកាន់តែសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និង អនុសញ្ញាទាំងឡាយរបស់អន្តរជាតិ ។

- សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីសិទ្ធិកុមារ និងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលជាស្ថាប័នទទួលខុសត្រូវអំពីសិទ្ធិកុមារ និងសិទ្ធិនារី ។

- គាំទ្រ សហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារ និងអភិវឌ្ឍន៍វិស័យសិទ្ធិមនុស្សនៅកម្ពុជា ។

គណៈកម្មការនេះ ពុំបានទទួលភារកិច្ចរៀបចំរបាយការណ៍ស្ដីពីការអនុវត្ត CEDAW នេះទេ គឺគ្រាន់តែចូលរួមពិនិត្យលើសេចក្ដីព្រាងរបាយការណ៍នេះ ហើយផ្ដល់យោបល់ ជូនរាជរដ្ឋាភិបាលដើម្បីសម្រេច ។

## មាត្រា ១ និង មាត្រា ២

**សំណួរទី២ : របាយការណ៍បាននិយាយថា "គ្រប់សិទ្ធិដូចដែលមានចែងនៅក្នុងកតិកាសញ្ញាសិទ្ធិមនុស្សអន្តរជាតិ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយគោលការណ៍ទាំងអស់នៃកតិកាសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្ស ត្រូវតែមានឥទ្ធិពលជាងច្បាប់ក្នុងប្រទេស(ទំព័រទី១៤)" ។ យោងទៅលើទំព័រទី៦១ នៃរបាយការណ៍ បានចែងថាច្បាប់ទាំងឡាយណាដែលពុំស្របទៅនឹងអនុសញ្ញា គឺពុំអាចអនុវត្តបានឡើយ ។ សូមបញ្ជាក់អោយបានច្បាស់អំពីការអនុវត្តអនុសញ្ញានៅក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេស និងសូមបញ្ជាក់អោយបានច្បាស់ថាតើអនុសញ្ញាត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងការដោះស្រាយករណីនៅក្នុងតុលាការដែរឬទេ? ហើយថាតើស្តង់ដាររបស់អនុសញ្ញាត្រូវបានយកទៅអនុវត្តនៅក្នុងច្បាប់ក្នុងប្រទេសដែរឬទេ?**

**ចម្លើយ ៖**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់គ្រឹះ ច្បាប់កំពូល ហេតុនេះ គ្រប់ច្បាប់ជាតិទាំងអស់ត្រូវតែស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ និងគោរពតាមគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។

មាត្រា ៣១ កថាខណ្ឌ័ទី ១ នៃរដ្ឋធម្មនុញ្ញបានចែងថា " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិការសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ" ។ ផ្អែកតាមខ្លឹមសារនេះ សបញ្ជាក់ឱ្យឃើញថា សិទ្ធិមនុស្សដែលបានចែងក្នុងមាត្រា ៣១ កថាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវបានទទួលយក និងការពារដោយរដ្ឋធម្មនុញ្ញ ដូច្នេះរាល់បញ្ញត្តិដែលត្រូវបានរដ្ឋធម្មនុញ្ញទទួលស្គាល់ហើយនោះ ត្រូវតែគោរព និងយកមកធ្វើជាគោលការណ៍សំរាប់ការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជាក់ស្តែងនៅក្នុងការដោះស្រាយរឿងក្តីនៅតាមតុលាការ ករណីខ្លះ ច្បាប់ជាតិពុំបានចែងឱ្យបានច្បាស់-លាស់ ថាតើត្រូវធ្វើការដោះស្រាយដោយឈរលើគោលការណ៍ណានោះទេ។ ប៉ុន្តែបែរជាមានចែងនៅក្នុងអនុសញ្ញាស្តីអំពីគោលការណ៍នោះទៅវិញ។ ក្នុងករណីនេះតុលាការបានយកគោលការណ៍នោះ មកធ្វើជាមូលដ្ឋានក្នុងការដោះស្រាយរឿងក្តី ។

ម្យ៉ាងទៀត ជារួមស្តង់ដាររបស់អនុសញ្ញាត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ នៅក្នុងព្រះរាជាណា-ចក្រកម្ពុជា ហើយរាល់ការតាក់តែងសេចក្តីព្រាងច្បាប់នានា ជាទូរទៅគឺតែងតែយកអនុសញ្ញានានា ដែលពាក់ព័ន្ធហើយត្រូវបានរដ្ឋធម្មនុញ្ញទទួលស្គាល់ហើយនោះ មកធ្វើជាមូលដ្ឋានក្នុងការតាក់តែង ដោយធ្វើយ៉ាងណាឱ្យច្បាប់ជាតិ និងអនុសញ្ញាមានលក្ខណៈស្រប និងស៊ីសង្វាក់គ្នា។

**សំណួរទី៣ ៖ របាយការណ៍បាននិយាយថាពាក្យ "ការរើសអើងប្រឆាំងនឹងស្ត្រី" គឺត្រូវបានគេទទួលស្គាល់និងប្រើនៅក្នុងច្បាប់ និងឯកសារច្បាប់(...) ប៉ុន្តែការអនុវត្តជាក់ស្តែងគឺនៅមានចន្លោះ (ទំព័រទី១៦)។ សូមបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែង ដែលបាននឹងកំពុងធ្វើ ដើម្បីបំពេញការខ្វះចន្លោះដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍។ ជាពិសេសសូមបញ្ជាក់អោយបានច្បាស់ បើសិនជាមានយន្តការសម្រាប់ទទួលពាក្យបណ្តឹង យន្តការសំរាប់ការដោះស្រាយ និងយន្តការសម្រាប់ការដាក់ទណ្ឌកម្មដើម្បីទប់ស្កាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងបញ្ជាក់អំពីការត្រួតពិនិត្យលើការអនុវត្តច្បាប់ទាំងឡាយណាដែលប្រឆាំងនឹងការរើសអើង?**

**ចម្លើយ ៖**

និយមន័យនៃពាក្យ "រើសអើងប្រឆាំងនឹងស្ត្រីភេទ" ត្រូវបានទទួលស្គាល់ ហើយត្រូវបានប្រើប្រាស់ក្នុងច្បាប់ និងលិខិតបទដ្ឋាន ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានការខ្វះខាតខ្លះលើគ្រប់វិស័យ ។ ជាក់ស្តែងនៅតាមការដ្ឋានសំណង់ កម្មករស្ត្រីដែលបំពេញការងារដូចបុរសដែរ តែងតែទទួលប្រាក់កម្រៃទាបជាងកម្មករជាបុរស ។

ករណីបែបនេះ ពុំមែនមានជាទូទៅនោះទេ គឺមានតែចំពោះការដ្ឋានដែលធ្វើការមិនជាប់លាប់ ហើយផ្តល់ប្រាក់កម្រៃប្រចាំថ្ងៃតែប៉ុណ្ណោះ ។ ករណីនេះ បើពិនិត្យឱ្យបានស៊ីជំរៅ ការធ្វើបែបនេះគឺពុំមែនឈរលើមូលដ្ឋាននៃការរើសអើងនោះទេ ពោលគឺការធ្វើបែបនេះដោយផ្អែកលើមូលដ្ឋានទិន្នផលការងាររបស់ស្ត្រីដែលមានពលកម្មខ្សោយផ្តល់នូវទិន្នផលការងារទាប ទើបទទួលបានប្រាក់កម្រៃទាបដែរ ព្រោះថាករណីបែបនេះគេក៏បានអនុវត្តចំពោះកម្មករជាបុរសដែលមានកម្លាំងពលកម្មខ្សោយចំពោះការងារនោះដែរ ។

បើនៅតាមរោងចក្រសហគ្រាសធំៗ ដែលដំណើរការងារជាប់ជាប្រចាំនោះ គឺពុំមានបែងចែកប្រាក់កម្រៃខុសគ្នារវាងបុរស និងស្ត្រីនោះឡើយ។ ប្រសិនបើមានការងារដូចគ្នា រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីលុបបំបាត់នូវចំណុចខ្វះខាតដែលអាចកើតមានឡើងនូវករណីការងារដូចគ្នា ទទួលបានកម្រៃខុសគ្នា គឺបានធ្វើការអប់រំឱ្យពួកគេយល់ : ឱ្យស្ត្រីបានយល់ពីតម្លៃការងាររបស់ខ្លួនដែលត្រូវទទួលបាននូវកម្រៃស្មើជាមួយនឹងបុរស ធ្វើឱ្យនិយោជកយល់ដឹងពីសិទ្ធិស្មើភាពរវាងបុរស និងស្ត្រីក្នុងគ្រប់វិស័យការងារ ។

នៅព្រះរាជាណាចក្រកម្ពុជាពុំមានយន្តការណាក្រៅពីតុលាការក្នុងការទទួលពាក្យបណ្តឹង ដោះស្រាយ និងដាក់ទណ្ឌកម្ម ដើម្បីទប់ស្កាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទទេ ។

**សំណួរទី៤ : របាយការណ៍បង្ហាញអំពីសេចក្តីព្រាងច្បាប់មួយចំនួន ។ ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ទាំងនេះ សូមផ្តល់ព័ត៌មានអំពីស្ថានភាពបច្ចុប្បន្នមានដូចជា ពង្រាងក្រមព្រហ្មទណ្ឌ នីតិវិធីក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការចាប់ជំរិត ការជួញដូរ និងការធ្វើអាជីវកម្មមនុស្ស និងសេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការសុំយកកូនទៅចិញ្ចឹមសម្រាប់ជនបរទេស។ បើសិនជាច្បាប់ទាំងនេះពុំទាន់ទទួលបានការអនុម័តនោះទេ សូមផ្តល់ព័ត៌មានអំពីពេលវេលាដែលច្បាប់ទាំងនេះនឹងទទួលបានការអនុម័ត?**

**ចម្លើយ :**

ស្ថានភាពនៃសេចក្តីព្រាងច្បាប់មួយចំនួនមានដូចខាងក្រោមនេះ :

- សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។ បច្ចុប្បន្នកំពុងរៀបចំដាក់ប្រជុំអន្តរក្រសួង ។

- សេចក្តីព្រាងច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ដែលកំពុងពិភាក្សាក្នុងកិច្ចប្រជុំអន្តរក្រសួង ។

- សេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីហើយៗ ក៏បានឆ្លងយោបល់អន្តរក្រសួងរួចហើយដែរ ប៉ុន្តែក្រសួងកិច្ចការនារីស្នើសុំបំពេញបន្ថែមចំណុចមួយចំនួនទៀត។ លុះមានការឯកភាពគ្នាហើយ យើងខ្ញុំនឹងដាក់ជូនសុំសេចក្តីសម្រេចពីគណៈរដ្ឋមន្ត្រី។

- សេចក្តីព្រាងច្បាប់ស្តីពីការសុំកូនទៅក្រៅប្រទេស បានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។

សេចក្តីព្រាងច្បាប់ទាំងអស់ខាងលើ ពុំទាន់អាចកំណត់ពេលវេលានៃការអនុម័តបានឡើយ គឺអាស្រ័យទៅតាមពេលវេលារបស់សមាជិកសភា ។

- សេចក្តីព្រាងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានរដ្ឋសភាធ្វើការអនុម័តនាថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៥ ហើយព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥។

**សំណួរទី៥ : សូមបញ្ជាក់អោយបានច្បាស់អំពីតួនាទីរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងកម្រិតធនធានមនុស្ស និងហិរញ្ញវត្ថុដែលក្រសួងកិច្ចការនារីមាន ។ ជាពិសេសសូមបញ្ជាក់អោយបានច្បាស់អំពីទំនាក់ទំនង និងកំរិតនៃភាពជាក់ពន្ធ័គ្នាជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលក្រុមប្រឹក្សានេះគឺជាយន្តការថ្នាក់ជាតិជាន់ខ្ពស់ ដែលមានតួនាទីតាមដាន និងពិនិត្យលើការអនុវត្ត ស៊ី ដ (ទំព័រទី២០) ហើយគណៈកម្មការសិទ្ធិមនុស្ស គឺមានតួនាទីសរសេរសេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិមនុស្ស ដើម្បីដាក់ជូនទៅអង្គការសហប្រជាជាតិ(ទំព័រទី១២) ។ សូមបញ្ជាក់អោយបានច្បាស់អំពីអំណាច និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងបីអំពីកិច្ចសហការរវាងស្ថាប័នទាំងបីនេះ និងអំពីការគាំទ្រ (ប្ញូរធនាសម្ពន្ធ័) របស់ស្ថាប័នទាំងបីនេះនៅថ្នាក់មូលដ្ឋាន?**

**ចម្លើយ:**

១- ក្រសួងកិច្ចការនារីមានមន្ត្រីនៅថ្នាក់កណ្តាលចំនួន១៨៤នាក់ ក្នុងនោះស្ត្រីមានចំនួន ១៣៨នាក់ បុរសចំនួន ៤៦នាក់ និងមន្ត្រីតាមបណ្តាខេត្តក្រុងទាំង២៤ សរុបមានចំនួន ៦៩៥នាក់ ក្នុងនោះនារីមានចំនួន៦៣៦នាក់ បុរសចំនួន៥៩នាក់។ក្នុងឆ្នាំ២០០៥នេះ ក្រសួងបានទទួលថវិកាជាតិចំនួន ៧.០២០លានរៀល សម្រាប់ធានាការផ្តល់ប្រាក់ខែដល់មន្ត្រីរាជការថ្នាក់កណ្តាល ដំណើរការក្រសួង សម្ភារៈផ្សេងៗសម្រាប់ក្រសួង (Office Equipment) និងផ្តល់សម្ភារៈ និងថវិកាមួយចំនួនដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី (WID) តាមបណ្តាខេត្ត-ក្រុង ដើម្បីបណ្តុះបណ្តាលស្ត្រី និងយុវតី ដែលក្រីក្រជួបការលំបាក។

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន (ក.ក.ន.អ) គឺជាស្ថាប័នជាតិ ដែលរាជរដ្ឋាភិបាលបានបង្កើតឡើងនៅឆ្នាំ ១៩៩៣ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា និងមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិ ដើម្បីធានាឱ្យស្ត្រីទទួលបាននូវផលប្រយោជន៍ដូចបុរស និងលើកកម្ពស់ស្ថានភាពស្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងការពារផលប្រយោជន៍ និងសិទ្ធិរបស់ស្ត្រី។ ក្រសួងកិច្ចការនារីមានតួនាទីជាអ្នកជំរុញ និងសម្របសម្រួលជាមួយស្ថាប័ន រដ្ឋាភិបាលផ្សេងៗទៀត សង្គមស៊ីវិល និងសហគមន៍ អ្នកផ្តល់ជំនួយ ដើម្បីការអភិវឌ្ឍន៍ស្ត្រីតាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ស្ថាប័នទាំងនេះ។

២- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាយន្តការជាតិអន្តរក្រសួងសម្របសម្រួលសំរួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហាដែលទាក់ទងដល់ការលើកកម្ពស់ស្ថានភាព តួនាទីរបស់ស្ត្រី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងអំពើហិង្សាលើស្ត្រី ក្នុងនោះមានភារកិច្ចជាអាទិ៍ :

- ជួយរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល តាមដាន វាយតំលៃការអនុវត្ត និងផ្តល់អនុសាសន៍ក្នុងគោលបំណងគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយជាតិ ច្បាប់បទបញ្ជា និងវិធានការ ដែលទាក់ទងដល់ការលើកកម្ពស់ ស្ថានភាព តួនាទី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា ។

- ជួយរាជរដ្ឋាភិបាលក្នុងការតាមដានការអនុវត្តសន្ធិសញ្ញាអន្តរជាតិនានា ពាក់ព័ន្ធទៅនឹងសិទ្ធិនារី និងការអនុវត្តច្បាប់ជាតិដែលទាក់ទងដល់ការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងបទប្បញ្ញត្តិច្បាប់នានាដែលទាក់ទងដល់ស្ត្រី ដើម្បីផ្តល់យោបល់លើកអនុសាសន៍ ឬសុំធ្វើវិសោធនកម្មតាមករណីជាក់ស្តែង ដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកាន់តែប្រសើរឡើង ។

- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនៅព្រះរាជាណាចក្រកម្ពុជា និងពិនិត្យផ្តល់យោបល់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច មុននឹងផ្ញើទៅអង្គការសហប្រជាជាតិ ។

- តាមដាន និងជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។

៣- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) ជួយរាជរដ្ឋាភិបាលរក្សាការពារអភិវឌ្ឍន៍ និងលើកតម្កើងវិស័យសិទ្ធិមនុស្សនៅកម្ពុជា និងរៀបចំរបាយការណ៍ ស្តីពីសិទ្ធិមនុស្សមួយចំនួនជូនរាជរដ្ឋាភិបាលដាក់ទៅអង្គការសហប្រជាជាតិមាន :

- របាយការណ៍ ស្តីពីការអនុវត្តកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

- របាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ។

- របាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីការប្រឆាំងអំពើទារុណកម្ម ។

- របាយការណ៍ ស្តីពីការអនុវត្តកតិកាសញ្ញា ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

របាយការណ៍បីខាងលើ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជូនរបាយការណ៍លើកដំបូងជូនអង្គការសហប្រជា-ជាតិពិនិត្យរួចហើយ ។

បច្ចុប្បន្ន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា កំពុងធ្វើសេចក្តីព្រាងរបាយការណ៍លើកដំបូង ស្តីពីការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គឺជួយរដ្ឋាភិបាលលើកស្ទួយការអនុវត្តសិទ្ធិមនុស្ស ទំនាក់ទំនង និងសហការជាមួយ CNCC-MOWA-CNCW ដើម្បីពង្រឹង និងលើកតម្កើងវិស័យសិទ្ធិកុមារ និងសិទ្ធិនារី ។

**សំណួរទី៦ : សូមបញ្ជាក់អោយបានច្បាស់ ថាតើមានដំណើរការវាយតំលៃលើការអនុវត្តផែនការប្រាំឆ្នាំ “នារីរតនៈ” ដែលផែនការនេះផ្តោតលើការកសាងសមត្ថភាពរបស់ស្ត្រី តាមរយៈវិស័យអប់រំ វិស័យសុខភាព កិច្ចការការពារផ្លូវច្បាប់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (ទំព័រទី២៣) ជាពិសេសក្នុងគោលបំណងដើម្បីធ្វើការប៉ាន់ប្រមាណអំពីឥទ្ធិពលនៃការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យ ហើយបើសិនជាបានដំណើរការ ការវាយតំលៃ សូមជួយផ្តល់ព័ត៌មានអំពីលទ្ធផលនៃការវាយតម្លៃនោះផង ?**

**ចម្លើយ :**

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានរៀបចំផែនការយុទ្ធសាស្ត្រប្រាំឆ្នាំលើកទី១របស់ខ្លួនហៅថា ”**នារីរតនៈ** ” ផែនការនេះផ្តោតទៅលើការកសាងសមត្ថភាពរបស់ស្ត្រី តាមរយៈវិស័យអប់រំ សុខភាព កិច្ចការពារផ្លូវច្បាប់ និងការអភិវឌ្ឍន៏សេដ្ឋកិច្ច ។

នៅក្នុងមហាសន្និបាតរបស់ក្រសួង ខែមេសា ឆ្នាំ២០០៣ ដែលចូលរួមដោយតំណាងរបស់ក្រសួងនៅថ្នាក់ជាតិ និងមន្ទីរខេត្ត-ក្រុង ដើម្បីបូកសរុបវាយតម្លៃការអនុវត្តផែនការប្រាំឆ្នាំ ”**នារីរតនៈ**” មហាសន្និបាតបានរកឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ និងភាពប្រឈម ព្រមទាំងកំណត់នូវទិសដៅសម្រាប់អនាគត ។ ជាលទ្ធផលក្នុងវិស័យសុខភាព ក្រសួងបានអនុវត្តនូវកម្មវិធីសុខភាពបន្តពូជដោយបានជ្រើសរើសយកខេត្តចំនួន៨ និងស្រុកចំនួន៧០ ដោយមានអ្នកស្ម័គ្រចិត្តជាស្ត្រីចំនួន ៨០០នាក់ ចូលរួមផង ។ ក្នុងកម្មវិធីនេះ មានការបណ្តុះបណ្តាលឱ្យស្ត្រីយល់ដឹងអំពីព័តិមានការប្រឹក្សា និងការផ្តល់សម្ភារៈគាំទ្រចំពោះស្ត្រីក្នុងវ័យបន្តពូជ ( ១៥-៤៩ឆ្នាំ ) ។ ផ្អែកទៅលើលទ្ធផលជាវិជ្ជមានគឺស្ត្រី និងក្មេងស្រី មានការយល់ដឹង និងបានប្រើប្រាស់សិទ្ធិដែលទាក់ទិនការទទួលបាននូវសេវា-កម្មសុខភាព និងចំណេះដឹងជាមូលដ្ឋានផ្នែកសុខភាពបឋម ជាពិសេស សុខភាពបន្តពូជ និងការបង្ការមេរោគអេដស៍ ។ សំខាន់ទៅទៀតនោះ ស្ត្រីទទួលបានចំណេះដឹងអំពីការគាំពារមាតា និងទារក ដើម្បីជួយកាត់បន្ថយអត្រាមរណភាពមាតា ទារក និងអំពីការសង្គ្រោះបន្ទាន់ ជាពិសេសនៅជនបទ ។

ក្នុងវិស័យអប់រំ ស្ត្រី និងក្មេងស្រី ទទួលបាននូវសិទ្ធិពេញលេញក្នុងការអប់រំគ្រប់កំរិតនិងជំនាញ ដើម្បីឱ្យក្លាយខ្លួនទៅជាធនធានមនុស្សដ៏សកម្មក្នុងសង្គម ។ ចំណុចដែលគួរអោយកត់សំគាល់គឺ ទិន្នន័យ អំពីបញ្ហាយេនឌ័រ និងការអប់រំស្ត្រី និងក្មេងស្រី ទាំងក្នុងប្រពន្ធ័ និងក្រៅប្រពន្ធ័ត្រូវបានចងក្រង និងប្រើប្រាស់ ។ នៅតាមសហគមន៏ក៏មានការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំក្មេងស្រី ការថែទាំការអប់រំកុមារតូចៗ ។ ចំនួនសិស្សស្រីចាប់ពីកំរិតបឋមសិក្សារហូតដល់ឧត្តមសិក្សា បានចុះឈ្មោះចូលរៀន និងការនៅរៀនជាប់លាប់កាន់តែកើនឡើងជាលំដាប់ ។ ចំពោះកម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រពន្ធ័សម្រាប់ស្ត្រី និងក្មេងស្រីត្រូវបានបង្កើត និងយកចិត្តទុកដាក់ខ្ពស់ ។

ក្នុងវិស័យកិច្ចការពារផ្លូវច្បាប់ ធានាថាស្ត្រី និងក្មេងស្រី ត្រូវទទួលបាននូវការការពារប្រកបដោយសមភាព សមធម៌ ហើយសិទ្ធិត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើច្បាប់ ការអនុវត្តច្បាប់ ការបណ្តុះបណ្តាលច្បាប់ និងការអប់រំ ។សមិទ្ធិផលសម្រេចបានគឺ មន្ត្រីបុគ្គលិកក្រសួង និងស្ត្រីនៃស្ថាប័នពាក់ពន្ធ័ទទួលបាននូវការបណ្តុះបណ្តាលផ្នែក

ច្បាប់ដែលទាក់ទិនទៅនឹងការជួញដូរស្ត្រី និងកុមារ អំពើហិង្សាប្រឆាំងស្ត្រី និងកុមារ និងយល់ដឹងពីបទពិសោធន៍លើការងារផ្នែកច្បាប់ថែមមួយកំរិតទៀត។ ម្យ៉ាងវិញទៀតដោយសារមានកិច្ចសហការល្អរវាងក្រសួង និងសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល ទើបទិន្នន័យទាក់ទងនឹងអំពើហិង្សាទៅលើស្ត្រី និងកុមារ និងការរើសអើងប្រឆាំងស្ត្រី និងកុមារត្រូវបានរៀបចំ។

ក្នុងវិស័យសេដ្ឋកិច្ច ស្ត្រីទទួលនូវសិទ្ធិស្មើភាព ក្នុងការទទួលបាននូវធនធានសេដ្ឋកិច្ច និងឱកាសចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ។ លទ្ធផលដែលគួរឱ្យកត់សំគាល់នោះ គឺស្ត្រីចេះទទួលខុសត្រូវ និងហ៊ានធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសមុខរបរផ្ទាល់ខ្លួនរបស់ពួកគេ។

ស្ត្រីបានយល់ដឹងអំពីសមត្ថភាពផ្នែកឥណទាន សហគ្រាស ជំនួញទីផ្សារ កសិកម្ម នេសាទ ។ល។ ដែលអាចឈានដល់ការបង្កើតក្រុមអ្នកប្រកបមុខរបរ និងសមាគមន៍នារីពាណិជ្ជករទៀតផង។

អំពីការកសាងសមត្ថភាព ក្រសួងបានជ្រើសរើសយកការកសាងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ ភាពជឿជាក់លើខ្លួនឯង និងចំណេះដឹងផ្នែកច្បាប់។ ទន្ទឹមនឹងនោះ ក៏មានការស្វែងរកការគាំទ្រមតិពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃស្ថាប័នកំពូល និងអ្នកមានតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់កំរិត ដើម្បីឱ្យជួយគាំទ្រការអនុវត្តគោលនយោបាយ និងកម្មវិធីនានាក្នុងការលើកកំពស់ ស្ថានភាព ឋានៈ តួនាទីរបស់ស្ត្រី ឆ្ពោះទៅរកសមភាព សមធម៌ នៅក្នុងសង្គមកម្ពុជា។

តាមរយៈលទ្ធផលខាងលើ ការបញ្ជ្រាបយេនឌ័រ និងការយល់ដឹងអំពីយេនឌ័រ ទៅលើវិស័យអាទិភាពខាងលើនេះ មានការកើនឡើងក្នុងចំណោមស្ថាប័នថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ប៉ុន្តែថ្វីបើការបញ្ជ្រាបយេនឌ័រជាគោលនយោបាយរបស់រាជរដ្ឋាភិបាលក៏ដោយ ក៏ការយល់ដឹង និងការគាំទ្រការបញ្ជ្រាបយេនឌ័រក្នុងគោលនយោ-បាយ និងកម្មវិធីរបស់ខ្លួនគឺ នៅមានកំរិតនៅឡើយ នៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធខ្លះ។

## មាត្រា ៣

**សំណួរទី៧ : របាយការណ៍បាននិយាយថា ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥ ហើយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏បានខិតខំបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយតាមវិស័យថ្នាក់ជាតិមានដូចជា ផែនការអភិវឌ្ឍន៍សង្គមកិច្ច សេដ្ឋកិច្ចលើកទី២ ឆ្នាំ២០០១-២០០៥ (ទំព័រទី៣៩)។ សូមផ្តល់ព័ត៌មានបង្ហាញ ថាតើអនុ-សញ្ញា ត្រូវបានគេយកទៅពិចារណានៅក្នុងយុទ្ធសាស្ត្រនេះបានដល់កម្រិតណា? និងសូមរៀបរាប់អំពីការអនុវត្តយុទ្ធសាស្ត្រនេះ និងការវាយតំលៃអំពីផលប៉ះពាល់នៃការអនុវត្តយុទ្ធសាស្ត្រនេះទៅលើសមភាពយេនឌ័រ។ សូមបង្ហាញផងដែរ ថាតើមានការចូលរួមរបស់សង្គមស៊ីវិល និងជាពិសេសក្រុមស្ត្រី រួមមានស្ត្រីដែលមកពីតំបន់ជន-**

**ជាតិភាគតិច និងជាស្ត្រីក្រីក្រនៅក្នុងដំណើរការរៀបចំសេចក្តីព្រាង និងការពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រនេះដែរឬទេ?**

**ចម្លើយ :**

ជាការពិតណាស់ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន (បច្ចុប្បន្នហៅថា ក្រសួងកិច្ចការនារី) បានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ និងបានខិតខំបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយតាមវិស័យថ្នាក់ជាតិដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី២ ឆ្នាំ ២០០១-២០០៥ ពីព្រោះថា ការលុបបំបាត់គំលាតយេនឌ័រ ជាកត្តាមួយក្នុងការកាត់បន្ថយភាពក្រីក្រ។

-ក្នុងដំណើរការនេះ ក្រសួងបានយកស្មារតី **ស៊ី ៩** ពាក់ព័ន្ធវិស័យអប់រំ សុខភាព សេដ្ឋកិច្ច សង្គម ដីធ្លី ការពារផ្លូវច្បាប់ ការងារបញ្ចូលទៅក្នុងឯកសារទាំងនោះ។ (សូមជូនភ្ជាប់ឯកសារ)

-ជាមួយការខិតខំប្រឹងប្រែងនេះ ធនាគារពិភពលោកបានសរសើរថា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា គឺជាឯកសារដែលឆ្លើយតបទៅនឹងយេនឌ័រល្អជាងគេបំផុត ( A most gender responsive NPRS) ។

-រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម (Council for Social Development) ដើម្បីតាមដានការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG)។

-ដើម្បីអាចវាស់វែង វាយតំលៃការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NSPR) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ក្រសួងកិច្ចការនារី ដោយសហការជាមួយក្រសួងពាក់ព័ន្ធទាំងអស់ និងមានការជួយឧបត្ថមពី UNIFEM, WB, ADB និង DFID / UK **បានរៀបចំឯកសារចំណែកស្មើភាពសម្រាប់នារី / ការវាយតម្លៃយេនឌ័រនៅកម្ពុជា** ( A Fair Share for Women / Cambodia Gender Assessment )។

-នៅចុងឆ្នាំ ២០០៤ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការតាមដានវាយតម្លៃ រាជរដ្ឋាភិបាលបានបញ្ចូលឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច (SEDP) ជាមួយយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឱ្យរលូនជាមួយ (CMDG)។ ក្រសួងកិច្ចការនារីបានបញ្ជ្រាបយេនឌ័រទៅក្នុងឯកសារនយោបាយដ៏មានសារៈសំខាន់នេះហើយ។

សង្គមស៊ីវិល និងក្រុមរបស់នារី បានចូលរួមនៅក្នុងការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០០១-២០០៥។ ដំណើរការនេះ រួមមានការប្រជុំពិគ្រោះយោបល់ ដែលរៀបចំឡើងដោយក្រសួងកិច្ចការនារី និងអង្គការក្រៅរដ្ឋាភិបាល នៅក្នុងខេត្តចំនួន ៤ នៅក្នុងនោះ ក្រុមស្ត្រីក្រីក្រចូលរួមផងដែរ ក៏ដូចជាការចូលរួមនៅក្នុងវេទិកាពិគ្រោះយោបល់ថ្នាក់ជាតិ និងសិក្ខាសាលា។ ចំពោះការពិគ្រោះយោបល់ ដោយផ្តោតទៅលើគោលដៅពិសេស ដែលជាក្រុមជនជាតិភាគតិច យើងពុំទាន់មានលទ្ធភាពមធ្យោបាយនៅឡើយ។

**មាត្រា ៤**

**សំណួរទី៨ : នៅក្នុងមាត្រា៤ របាយការណ៍បង្ហាញអំពីព័ត៌មានស្តីពីវិធានការផ្នែកច្បាប់មួយចំនួន (មានដូចជាមាត្រាមួយចំនួននៅក្នុងរដ្ឋធម្មនុញ្ញ រួមមានមាត្រា៧៣ និងមាត្រា៤៦.៣ គោលនយោបាយពិសេស ស្តីពីវិស័យអប់រំ និងការងារច្បាប់ស្តីពីប្រាក់ចូលនិវត្តន៍) ដែលពុំមែនជាវិធានការពិសេសបណ្តោះអាសន្នស្របទៅនឹងមាត្រា៤ កថាខណ្ឌទី១ នៃអនុសញ្ញានោះទេ។ ដូច្នេះសូមផ្តល់ព័ត៌មាន ស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តវិធានការពិសេសជាបណ្តោះអាសន្ន ដើម្បីទទួលបាននូវសមភាពជាក់ស្តែងរវាងបុរសនិងស្ត្រី ដូចដែលអនុសាសន៍ទូទៅលេខ២៥ របស់គណៈកម្មាធិការ ស៊ី ដ បានចែង?**

**ចម្លើយ :**

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងកិច្ចការពារសិទ្ធិមនុស្សរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីទទួលបាននូវសិទ្ធិសមភាពលើគ្រប់វិស័យជាមួយនឹងបុរស។

ដើម្បីសម្រេចបាននូវទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការស្វែងរកវិធានការពិសេសនានាសំរាប់ជំរុញស្ត្រីអោយឆាប់ទទួលបាននូវសិទ្ធិសមភាពនេះ។ ដូចនេះរាជរដ្ឋាភិបាលកម្ពុជា សូមបង្ហាញជូននូវការអនុវត្តវិធានការមួយចំនួនក្នុងវិស័យអប់រំ ដើម្បីអោយនារីកម្ពុជាមានលទ្ធភាពទទួលបានការសិក្សាដែលមានដូចខាងក្រោមនេះ÷

-ការផ្តល់អាហារូបករណ៍ដល់សិស្សស្រីក្រីក្រនៅតំបន់ជនបទ តំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងជនជាតិភាគតិច មានសិស្សស្រីសរុបចំនួន ៦០.៣៧៤ នាក់ គិតជាភាគរយ ២៦,២៤%។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាមធ្យមសិក្សាបឋមភូមិចំនួន ២១៥ ក្នុងខេត្ត-ក្រុងចំនួន ១៧ ក្នុងឆ្នាំ ២០០៣-២០០៤ ។

-ការលុបបំបាត់ចំណាយក្រៅផ្លូវការរបស់មាតាបិតា និងអាណាព្យាបាលសិស្សសម្រាប់ក៏រិតអប់រំមូលដ្ឋានដោយរដ្ឋបង្កើនថវិកាដំណើរការសាលារៀន ។

-ការផ្តល់អាទិភាពឱ្យគ្រូស្រីចេញថ្មី បានជ្រើសរើសប៉ុស្តិ៍ដែលអាចទៅបម្រើការងារបានចៀសវាងប៉ុស្តិ៍ជួបការលំបាក ដាច់ស្រយាលដែលអាចប៉ះពាល់ដល់សុខសុវត្ថិភាពផ្ទាល់ខ្លួន។

-ការផ្តល់ឱកាសឱ្យសិស្សស្រីពិការបានចូលរៀននៅមជ្ឈមណ្ឌលកុមារពិការ ដោយមានការផ្តល់អាហារូបករណ៍ និងការយកចិត្តទុកដាក់លើការរស់នៅ ហូបចុក ស្លៀកពាក់ យ៉ាងសមរម្យ។

-ការកសាងអន្តេវាសិកដ្ឋាន នៅតំបន់ដាច់ស្រយាល តំបន់ជនបទ តំបន់ជួបការលំបាក ( ខេត្តមណ្ឌលគីរីមានបីអន្តេវាសិកដ្ឋាន ) វិទ្យាល័យកំពង់ឈើទាលមាន១កន្លែង និងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាចំនួន៩កន្លែង សម្រាប់ផ្តល់ឱកាសដល់សិស្សស្រីក្រីក្របានចូលរៀនដែលមានចំនួនសរុបសម្រាប់សាលាចំណោះ-

ទូទៅ ១.០៨៣នាក់ គិតជាភាគរយ ៣០,០៤% គ្រឹះស្ថានឧត្តមសិក្សា ២៨២នាក់ គិតជាភាគរយ ៤០,៦៣ % ។

-នៅគ្រប់សាលាគរុកោសល្យខេត្ត/ក្រុងទាំង១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានអន្តេវាសិកដ្ឋានសម្រាប់គរុសិស្សស្រីនៃគ្រួសារក្រីក្រមកពីខេត្ត-ក្រុងផ្សេងៗ និងតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក តំបន់ជនបទ តំបន់ជនជាតិភាគតិច ដែលមានគរុសិស្សស្រីសរុបចំនួន ១០៩១ នាក់ គិតជាភាគរយ ៤២,៦៦% ។

-រាជរដ្ឋាភិបាលបានអនុវត្តគោលការណ៍ជួយឧបត្ថម្ភ ជាពិសេសដល់មាតាដែលមានកូនភ្លោះបីនាក់ ។

## មាត្រា ៥

**សំណួរទី៩ : នៅក្នុងរបាយការណ៍ទាំងមូល តែងតែមានការនិយាយថា បញ្ហាចាក់ឫសពីវប្បធម៌ និងសង្គមតំរិយាបថ និងផ្នត់គំនិត គឺជាឧបសគ្គរារាំងដល់ស្ត្រីក្នុងការទទួលបានការអប់រំ ជាមូលហេតុដែលបណ្តាលឱ្យអត្រាបោះបង់ចោលសាលារបស់ក្មេងស្រីមានកម្រិតខ្ពស់ ជាឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយ និងការងារក្នុងវិស័យសាធារណៈជាឧបសគ្គក្នុងការទទួលបានសេវាសុខភាព និងជាមូលហេតុនាំអោយមានការរើសអើង ដូចជាត្រូវរៀបការទាន់នៅវ័យក្មេង និងអាពាហ៍ពិពាហ៍ដោយមានការរៀបចំ (ទំព័រទី២៨,៤០, ៤១,៥៣,៦៧)។ លើសពីនេះទៀត របាយការណ៍បានរៀបរាប់ថា ពុំទាន់មានការផ្សព្វផ្សាយព័ត៌មាន និងការអប់រំយ៉ាងទូលំទូលាយនៅឡើយទេ អំពីការផ្លាស់ប្តូរទំនៀមទំលាប់ ប្រពៃណីចាស់ដែលពុំគួរនឹងទទួលយកទៀត(ទំព័រទី២៨)។ សូមផ្តល់ព័ត៌មាន ថាតើរដ្ឋាភិបាលមានយុទ្ធសាស្ត្រ ឬមានគំរោងនឹងអនុម័តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដែលយុទ្ធសាស្ត្រនេះមានគោលដៅលើស្ត្រីក្រីក្រគ្មានទីពឹង ស្ត្រីមកពីតំបន់ជនបទ និងស្ត្រីជនជាតិភាគតិចក្នុងគោលបំណងលុបបំបាត់ផ្នត់គំនិតចាស់ដែលមានការរើសអើងប្រឆាំងនឹងស្ត្រី និងសូមផ្តល់ព័ត៌មានអំពីស្ថានភាពរីកចំរើនដែលទទួលបានពីការអនុវត្តយុទ្ធសាស្ត្រនេះ?**

**ចម្លើយ :**

រាជរដ្ឋាភិបាលបានកត់សម្គាល់ឃើញថា ក្នុងសង្គមកម្ពុជានាដើម ស.វ.នៃគ.ស.ព្រះនាងសោមា ឬនាងនាគបានបង្កើតរដ្ឋ និងអារ្យធមិនគរភ្នំ ជាអារ្យធមិមុនគេនៅតំបន់អាស៊ីអគ្នេយ៍ដីគោក។ តាំងពីពេលនោះមកសង្គមកម្ពុជាបានអនុវត្តនូវរបបមាតាធិបតេយ្យ គឺលើកតម្កើងស្ត្រីជាធំ ហើយរបបនេះមានឥទ្ធិពលរហូតមកដល់សព្វថ្ងៃក្នុងភាសាខ្មែរ ក្នុងប្រពៃណីទំនៀមទម្លាប់ វិស័យអប់រំ និងអ្នកដឹកនាំសង្គម ដូចជាពាក្យប្រទេសខ្មែរហៅថាមាតុភូមិ(ភូមិរបស់មាតា) ខាងប្រពៃណី ប្រុសត្រូវចូលស្តីដណ្តឹងស្រី វិស័យអប់រំខ្មែរប្រើពាក្យ មេរៀន មេសូត្រ មេលេខ ឯការហៅអ្នកដឹកនាំតាមថ្នាក់ខ្មែរ ប្រើពាក្យ មេ ដូចជា មេស្រុក មេឃុំ មេភូមិ ។ លទ្ធផលក្នុងការ

អនុវត្តរបបមាតាធិបតេយ្យធ្វើឱ្យសង្គមរីកចំរើន តាំងពីសម័យនគរភ្នំ ចេនឡា រហូតដល់សម័យអង្គរ។ ដូច្នេះប្រពៃណីខ្មែរ មិនរើសអើងស្ត្រីទេក្នុងគ្រួសារ និងក្នុងសង្គមជាតិ ហើយក៏គ្មានការលើកតម្កើងបុរសធំជាងស្ត្រីដែរ។

តែសព្វថ្ងៃនេះ មានបាតុភូតរើសអើងស្ត្រីដែលជាផ្នត់គំនិតថ្មីមិនមែនជាផ្នត់គំនិតចាស់របស់អ្នកស្រុកខ្មែរទេ។ បាតុភូតរើសអើងស្ត្រីនេះ ប្រហែលជាបាននាំចូលមកដោយអារ្យធម៌ វប្បធម៌បរទេស។ ការមើលងាយស្ត្រីគឺជាការមើលងាយវប្បធម៌ខ្មែរ និងជាន់ពន្លិចវប្បធម៌ខ្មែរ។ បញ្ហាដែលកម្ពុជាត្រូវបានទទួលរងការចោទប្រកាន់ថាមានការរើសអើងស្ត្រីនោះ ក៏ប្រហែលជាដោយសារស្រុកកើតកលិយុគច្រើនជាងបានសេចក្តីសុខ តាំងពីពេលនិរាសអង្គររហូតមកដល់ចុងសតវត្សទី២០ បង្កឱ្យមានអសន្តិសុខ អំពើហិង្សា ការភ័យខ្លាច ភាពក្រីក្រ ព្រាត់និរាសបែកបាក់គ្រួសារ រត់ភៀសខ្លួន ដែលធ្វើឱ្យអ្នកស្រុកទាំងប្រុស ទាំងស្រីមិនបានរៀនសូត្រចេះដឹងជ្រៅជ្រះ ហើយអ្នកដែលមិនបានរៀនសូត្រភាគច្រើនជាស្ត្រី។

នយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងនានា ចំពោះការប្រឆាំងនឹងការរើសអើងស្ត្រី គឺអនុវត្តនយោបាយ "**អភិវឌ្ឍន៍សង្គមវប្បធម៌សន្តិភាព** " ដើម្បីឱ្យមនុស្សខ្មែរជំនាន់ថ្មីមានការយល់ដឹងអំពីវប្បធម៌ និងប្រពៃណីខ្មែរពិតប្រាកដ ដែលស្របនឹងវប្បធម៌នៅអារ្យប្រទេសនានាដែរ ដើម្បីធ្វើឱ្យសង្គមជាតិយើងស្ថិតក្នុងសន្តិភាពជារៀងរហូត បង្កឱកាសឱ្យស្ត្រីខ្មែរមានសិទ្ធិរៀនសូត្រ សិទ្ធិប្រកបការងារ។ វប្បធម៌ខ្មែរជាវប្បធម៌លើកតម្កើងស្ត្រី និងជាវប្បធម៌សន្តិភាព។ សន្តិភាព និងការកាត់បន្ថយភាពក្រីក្រជាប្រភពនៃការមានសិទ្ធិរៀនសូត្រ។

តាមរយៈការអនុវត្តនយោបាយអភិវឌ្ឍន៍សង្គមវប្បធម៌សន្តិភាព សព្វថ្ងៃនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មាននារីចុះឈ្មោះកាន់តែមានចំនួនច្រើនឡើងៗ ហើយនាឆ្នាំ ២០០៥នេះ ក្នុងចំណោមនិស្សិតដែលប្រឡងបញ្ចប់បរិញ្ញាប័ត្រចំនួន ១.១៨៦នាក់ មាននិស្សិតជានារីចំនួន ២១១នាក់ ស្មើនឹង ១៨% គឺមានការកើនលើសពីឆ្នាំ២០០៤។ ចំពោះស្ត្រីក្រីក្រគ្មានទីពឹង រាជរដ្ឋាភិបាលបានលើកទឹកចិត្តផ្នែកឯកជន ឱ្យបង្កើតជាសិប្បកម្មត្បាញ-រវៃ ។សព្វថ្ងៃសិប្បកម្មត្បាញរវៃ បានកើតឡើងច្រើន នៅខេត្តសៀមរាប កំពង់ចាម ព្រៃវែង កណ្តាល តាកែវ បាត់ដំបង ។ល។ ដែលជាប្រភពបង្កើតការងារចំពោះស្ត្រី និងពិសេសស្ត្រីក្រីក្រ។ ឯស្ត្រីជនជាតិភាគតិចនៅខេត្តរតនគីរី និងមណ្ឌលគីរី ក៏មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តទាំងពីរបានជំរុញឱ្យមានបង្កើតសិប្បកម្មត្បាញ-រវៃតាមប្រពៃណីជនជាតិបង្កើតការងារជូនពួកគេបាន។

នាអនាគត រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តនយោបាយអភិវឌ្ឍសង្គមវប្បធម៌សន្តិភាពក្នុងគោលដៅប្រែក្លាយព្រះរាជាណាចក្រកម្ពុជាឱ្យទៅជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ខ្មែរ ដើម្បីឱ្យស្ត្រីបានរៀនសូត្រស្មើនឹងបុរស បង្កើតការងារជូនស្ត្រី និងបំបាត់ភាពក្រីក្រក្នុងសង្គមខ្មែរ ។

-លើយុទ្ធសាស្ត្រពង្រីកសាលារៀនឱ្យបានដល់ជិតផ្ទះចាប់ពីឆ្នាំ ២០០១ មានចំនួន ៦.៧៤២សាលារៀននៅតំបន់ជនបទ និង៩៤៦សាលារៀននៅតំបន់ដាច់ស្រយាល (សិស្សស្រីក្រីក្រមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងជនជាតិភាគតិច) ក្រសួងអប់រំ យុវជន និង កីឡា បានលើកគោលនយោបាយក្នុងឃុំមួយមានអនុ-

វិទ្យាល័យមួយ (Lower Secondary School) និងក្នុងមួយស្រុកយ៉ាងហោចណាស់មានវិទ្យាល័យមួយ (Upper Secondary School) ឬប្រែក្លាយសាលាបង្គោលក្នុងកម្រង សាលាបឋមសិក្សាឱ្យទៅជាអនុវិទ្យាល័យ ដើម្បីចៀសវាងកុំឱ្យសិស្សស្រីក្រីក្របោះបង់ចោលការសិក្សាដោយមូលហេតុផ្លូវឆ្ងាយ ឬខ្វះសុខសុវត្ថិភាព។

-ប្រការនេះអាចជួយសិស្សស្រីក្រីក្រ ពន្យារបាននូវអាពាហ៍ពិពាហ៍តាមការរៀបចំ និងអាចឆ្លងពីភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀតបាន។

-ការបង្កើនចំនួនគ្រូស្រី តាមរយៈការជ្រើសរើសសិស្សស្រីពីតំបន់ជនបទជួបការលំបាកតំបន់ដាច់ស្រយាល និងជនជាតិភាគតិច ដោយមានលក្ខខណ្ឌបន្ថយរូបមន្តពី ១២+២ (រៀនចប់ថ្នាក់ទី១២ និងបណ្តុះបណ្តាលរយៈពេល ២ឆ្នាំ) មក ៩+២ (ជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និង បណ្តុះបណ្តាលរយៈពេល២ឆ្នាំ ) ព្រមទាំងផ្តល់អាទិភាពដល់បេក្ខជនជានារីភេទ ដើម្បីទាក់ទាញសិស្សស្រីនៅតំបន់ទាំងនោះឱ្យចូលបម្រើវិជ្ជាជីវៈគ្រូបង្រៀនបានច្រើនចាប់ពីឆ្នាំ ១៩៩៣ មានចំនួន ៣៩,៥៤% លើចំនួនសរុប។

-នៅតាមសាលារៀន មានរៀបចំបង្គន់អនាម័យ សិស្សស្រីដោយឡែកពីបង្គន់សិស្សប្រុស។

-ការបង្កើនចំនួននាយិកា នាយិការង សាលាគ្រប់ភូមិសិក្សា និងមន្ត្រីគ្រប់គ្រងជានារី បានកើនរៀងរាល់ឆ្នាំ។

-ចំពោះក្រសួងដទៃទៀត ទទួលអនុវត្តគោលនយោបាយនេះយ៉ាងសកម្ម។

**សំណួរទី១០ : សូមផ្តល់ព័ត៌មានពិស្តារលើសេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ រួមទាំងពេលវេលាដែលបានគ្រោងសំរាប់ការអនុម័ត និងវិសាលភាពនៃច្បាប់ និងសូមបញ្ជាក់ថាតើ មានបទបញ្ញត្តិស្តីពីការដោះស្រាយផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៅក្នុងសេចក្តីព្រាងច្បាប់នេះដែរឬទេ? សូមផ្តល់ព័ត៌មានបញ្ជាក់ផងដែរ ថាតើទស្សនៈរបស់អង្គការរបស់ស្ត្រី និងសង្គមស៊ីវិលត្រូវបានបញ្ចូលទៅក្នុងដំណើរការសរសេរសេចក្តីព្រាងច្បាប់នេះដែរឬទេ?**

**ចម្លើយ :**

បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានក្លាយទៅជាច្បាប់ដោយពេញលក្ខណៈហើយ។

សេចក្តីព្រាងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះត្រូវបានដាក់ជូនសម័យប្រជុំពេញអង្គនៃរដ្ឋសភាពិនិត្យពិភាក្សាម្តងហើយកាលពីឆ្នាំ ២០០៣ នៃរដ្ឋសភា អាណត្តិទី២។ ប៉ុន្តែក្រោយមក ដោយបានពិចារណាទៅលើអនុសាសន៍ទាំងឡាយរបស់រដ្ឋសភា និងរបស់សង្គមស៊ីវិល សេចក្តីព្រាងច្បាប់នេះត្រូវបានកែសម្រួល ដោយផ្តល់សារៈសំខាន់ជាអាទិភាពដល់ការអប់រំ ជាជាងដល់ការផ្តន្ទាទោស។

សេចក្តីព្រាងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានទទួលការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា ក្នុងខែ កញ្ញា ឆ្នាំ ២០០៥ ហើយបានចូលជាធរមាននៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៥ មានគោលដៅច្បាស់លាស់ ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារគ្រប់រូបភាពទាំងអស់ និងការពារជនរងគ្រោះ។ អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ត្រូវបានគ្របដណ្តប់ដោយច្បាប់នេះ ដោយរាប់ទាំងអំពើហិង្សាផ្នែកសេដ្ឋកិច្ចផងដែរ។ ប្តី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវបានការពារដោយច្បាប់នេះ។ ម្យ៉ាងវិញទៀត ច្បាប់នេះអនុវត្តទៅលើបុគ្គលទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងស្ថិតនៅក្នុងបន្ទុកគ្រួសារតែមួយ។

ដើម្បីផ្តល់កិច្ចការពារមួយប្រកបដោយប្រសិទ្ធភាពនោះ ច្បាប់នេះបង្កើតអោយមានវិធានការថ្មីៗដូចជាសេចក្តីសម្រេចរដ្ឋបាលអាចធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាសន្តិសុខជាបន្ទាន់ដល់ជនរងគ្រោះនៅក្នុងពេលដែលអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបម្រុងនឹងត្រូវកើតឡើង។ ច្បាប់នេះអនុញ្ញាតឱ្យចៅក្រមចេញដីកាការពារដែលក្នុងជំហ៊ានដំបូងមានរយៈពេល២ខែ ហើយបើមានការស្នើផ្សេងទៀតមានរយៈពេល៦ខែ ថែមទៀត។

ច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារកម្ពុជា អនុញ្ញាតឱ្យតុលាការចេញដីកាមួយដែលហៅថា ដីកាបំបែកលំនៅសង្វាស ប៉ុន្តែវិធានការច្បាប់នេះអាចអនុវត្តបានតែក្នុងករណីដែលមានការស្នើសុំលែងលះគ្នាតែប៉ុណ្ណោះ។ ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែលមិនចង់ដាក់ពាក្យបណ្តឹងសុំលែងលះគ្នា មិនអាចទទួលបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាព ដោយក្របខណ្ឌច្បាប់កម្ពុជានៅពេលបច្ចុប្បន្ននេះបានឡើយ។

ច្បាប់នេះ តម្រូវអោយអាជ្ញាធរមានសមត្ថកិច្ចធ្វើការផ្សព្វផ្សាយព័ត៌មានទាំងឡាយ ដែលទាក់ទងនឹងបទប្បញ្ញត្តិនានានៃច្បាប់នេះ ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងទម្រង់ទាំងឡាយនៃកិច្ចការពារតាមផ្លូវច្បាប់នៅទូទាំងប្រទេស។ ច្បាប់នេះក៏មានបទប្បញ្ញត្តិទាំងឡាយ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួង និងស្ថាប័ននានា ព្រមទាំងស្តីពីការបណ្តុះបណ្តាលដល់មន្ត្រី និងភ្នាក់ងារសង្គមស៊ីវិលនានាដែលធ្វើការនៅក្នុងវិស័យនេះ។

ច្បាប់នេះ ពុំមានបំណងបំបែកបំបាក់គ្រួសារទេ ផ្ទុយទៅវិញច្បាប់នេះនឹងពង្រឹងតម្លៃគ្រួសារខ្មែរ ហើយនិងជួយកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារអោយបានច្រើនជាអតិបរមា និងធានាសុវត្ថិភាពដល់គ្រួសារខ្មែរ។ ប៉ុន្តែបើអំពើហិង្សាក្នុងគ្រួសារទាំងឡាយណាដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

នៅគ្រប់ដំណាក់កាលនៃការសរសេរសេចក្តីព្រាងច្បាប់ ចាប់ពីឆ្នាំ ១៩៩៦ គឺមានការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល។ អនុសាសន៍ជាច្រើនត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់នេះ។

**សំណួរទី១១ : សូមផ្តល់ព័ត៌មានអំពីយុទ្ធសាស្ត្រផ្សេងៗទៀតដែលបាននិងកំពុងអនុវត្ត និងការរីកចម្រើនពីការអនុវត្តយុទ្ធសាស្ត្រទាំងនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីរួមមាន អំពើហិង្សា**

**ផ្លូវភេទ និងសូមផ្តល់ព័ត៌មានថាតើ មានយន្តការដែលមានប្រពន្ធ័ត្រឹមត្រូវសម្រាប់ការប្រមូលទិន្នន័យ និងព័ត៌មានអំពីបញ្ហានេះដែរឬទេ?**

**ចម្លើយ :**

ក្រសួងកិច្ចការនារីបានពិភាក្សារៀបចំផែនការយុទ្ធសាស្រ្តថ្នាក់ជាតិ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ និងសង្គមស៊ីវិល សម្រាប់ការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ផែនការយុទ្ធសាស្រ្តនោះមានសមាសភាគចំនួន៣ : ទី១ - ការផ្សព្វផ្សាយអំពីច្បាប់ ទី២ - ការផ្តល់សេវាដល់ជនរងគ្រោះ ទី៣ - ការបណ្តុះបណ្តាលដល់មន្រ្តីរាជការដែលអនុវត្តច្បាប់។ បច្ចុប្បន្ន ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះកំពុងត្រូវបានអនុវត្ត ដូច្នេះផែនការយុទ្ធសាស្រ្តនេះនឹងត្រូវពិនិត្យមើលឡើងវិញ និងចាំបាច់ត្រូវបន្ថែមផ្នែកមួយ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។ ទិន្នន័យស្តីពីអំពើហិង្សាប្រឆាំងនឹងស្រ្តីកំពុងត្រូវបានប្រមូល។ ក្រសួងកិច្ចការនារីនៅពុំទាន់មានយន្តការក្នុងការប្រមូលទិន្នន័យនៅឡើយ។ ជាមួយនឹងការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រសួងកិច្ចការនារីដកស្រង់ទិន្នន័យតាមរយៈឃុំ-សង្កាត់។ លើសពីនេះទៀតនឹងមានការប្រមូលទិន្នន័យពីក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃដើម្បីរៀបចំស្ថិតិជាតិ ស្តីពីអំពើហិង្សាប្រឆាំងនឹងស្រ្តី ដូចមានចែងក្នុងគោល-ដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា។

## មាត្រា ៦

**សំណួរទី១២ : របាយការណ៍បានបង្ហាញថា ក្រសួងមហាផ្ទៃកំពុងអនុវត្តកម្មវិធីតាមជំហានជាយុទ្ធសាស្រ្តចំនួន៣ ដើម្បីបង្ក្រាបអំពើជួញដូរ មានដូចជាការបង្កើនការស្វែងយល់អំពីបញ្ហា និងការឃ្លីកឃ្លើនដល់នគរបាលចៅក្រម និងព្រះរាជអាជ្ញា(ទំព័រទី២៩-៣០) ហើយរបាយការណ៍ក៏បានបង្ហាញផងដែរនូវវិធានការមួយចំនួនទៀតដែលត្រូវបានអនុវត្តដើម្បីរួមចំណែកក្នុងការស្តារ និងការធ្វើសមាហរណកម្មដល់ជនរងគ្រោះ(ទំព័រទី៣៣)។ សូមផ្តល់នូវព័ត៌មានពិស្តារ ស្តីពីឥទ្ធិពល/ផលប៉ះពាល់នៃវិធានការទាំងនេះទៅលើការទប់ស្កាត់អំពើជួញដូរស្រ្តី និងក្មេងស្រី និងជាពិសេសទៅលើការស្តារនីតិសម្បទាចំពោះជនរងគ្រោះដោយសារការជួញដូរ។ លើសពីនេះ សូមផ្តល់ព័ត៌មានពិស្តារ ស្តីពីការខិតខំប្រឹងប្រែងក្នុងការប្រមូលព័ត៌មាន ស្តីពីការជួញដូរនៅកម្ពុជា?**

**ចម្លើយ :**

I- <u>**ឥទ្ធិពល (Impact) នៃការអនុវត្តយុទ្ធសាស្រ្ត ០៣ជំហាន លើការទប់ស្កាត់ និង បង្ក្រាបអំពើការជួញដូរស្រ្តី និង ក្មេងស្រី :**</u>

វិធានការយុទ្ធសាស្រ្ត ០៣ជំហាន របស់ក្រសួងមហាផ្ទៃក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរភេទមានឥទ្ធិពលដូចតទៅ :

**១. ឥទ្ធិពលនៃការអនុវត្តនីតិវិធីប្រតិបត្តិការរបស់នគរបាលក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរស្ត្រី និងក្មេងស្រី :**

-បានធ្វើអោយយើងរកឃើញនូវអត្តសញ្ញាណពិតប្រាកដនៃជនរងគ្រោះដែលត្រូវគេជួញដូរ ព្រមទាំងជនប្រព្រឹត្តអំពើឧក្រិដ្ឋជួញដូរស្ត្រី និងក្មេងស្រី ។

-ស្ត្រី និងក្មេងស្រីជាច្រើនត្រូវបានជួយសង្គ្រោះ ហើយពួកឧក្រិដ្ឋជន ខ្សែរយៈចាត់តាំងទាំងក្នុង និងក្រៅប្រទេសត្រូវបានបង្ក្រាប និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។ ជាមួយគ្នានេះដែរ ទីតាំងធ្វើអាជីវកម្មផ្លូវភេទមួយចំនួនត្រូវបានរកឃើញ និងចាត់វិធានការតាមផ្លូវច្បាប់ ។

-ប្រតិបត្តិការបង្ក្រាបរបស់នគរបាល បានធ្វើអោយបណ្តាសមាសភាពដែលធ្លាប់ប្រព្រឹត្តអំពើជួញដូរស្ត្រី និងក្មេងស្រី និងទីតាំងអាជីវកម្មមួយចំនួនត្រូវបានផ្អាកសកម្មភាព ឬផ្លាស់ប្តូរមុខរបរ ។

-ដោយសារការអនុវត្តបានត្រឹមត្រូវតាមនីតិវិធីប្រតិបត្តិការរបស់នគរបាល បានធ្វើអោយដំណើរការកាត់ក្តីតាមផ្លូវតុលាការលើករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ត្រូវបានប្រព្រឹត្តទៅកាន់តែមានភាពរលូន ។

-បានធ្វើអោយបណ្តាសហគមន៍ បណ្តាស្ថាប័ន សង្គមស៊ីវិល និងប្រជាពលរដ្ឋមានជំនឿទុកចិត្តលើសមត្ថកិច្ច និងភ្ញាក់រលឹកចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។

● តាមរយៈសកម្មភាពខាងលើ បានធ្វើអោយអំពើជួញដូរស្ត្រី និងក្មេងស្រីក្នុងសង្គមកម្ពុជាត្រូវបានកាត់បន្ថយ ។

**២.ឥទ្ធិពលនៃការបង្កើនការយល់ដឹងពីអាជីវកម្មផ្លូវភេទក្នុងការទប់ស្កាត់ និងបង្ក្រាបការជួញដូរផ្លូវភេទ:**

ជំហាននេះត្រូវបានចាត់ទុកជាវិធានការសំខាន់ក្នុងចំណោមជំហានទាំង៣ ដែលមានឥទ្ធិពលដោយផ្ទាល់ដល់កិច្ចការបង្ការអំពើជួញដូរស្ត្រី និងក្មេងស្រី ។

សកម្មភាពជាក់ស្តែងត្រូវបានផ្តោតទៅលើការផ្សព្វផ្សាយច្បាប់ បទដ្ឋានពាក់ព័ន្ធ សភាពការណ៍ដែលកើតមានជូនដល់សហគមន៍ មជ្ឈមណ្ឌលសិក្សា និងសមាសភាពដែលងាយទទួលរងគ្រោះដោយសារអំពីជួញដូរ ។

-ធ្វើអោយប្រជាពលរដ្ឋគ្រប់ស្រទាប់ ពិសេសស្ត្រី និងកុមារដែលជាសមាសភាពងាយទទួលរងគ្រោះបានយល់ពីសភាពការណ៍ សកម្មភាព ល្បិចកល និងគ្រោះថ្នាក់ ព្រមទាំងផលវិបាកនានាដែលកើតឡើងពីអំពើជួញដូរ ហើយមានស្មារតីប្រុងប្រយ័ត្នចេះការពារខ្លួនអោយចាកផុតអំពើជួញដូរ ។

-ធ្វើអោយប្រជាពលរដ្ឋគ្រប់ស្រទាប់យល់ដឹងពីច្បាប់ និងវិធានការនានាក្នុងការទប់ស្កាត់ បង្ក្រាប និងចូលរួមអនុវត្តច្បាប់ ដើម្បីកាត់បន្ថយអំពើជួញដូរមនុស្ស ។

**៣. ឥទ្ធិពលនៃការហ្វឹកហ្វឺនស៊ីជម្រៅបច្ចេកទេសស៊ើបអង្កេតដល់នគរបាល ព្រះរាជអាជ្ញា និងចៅក្រមក្រុងភ្នំពេញ :**

ការហ្វឹកហ្វឺនបច្ចេកទេសស៊ើបអង្កេតដល់នគរបាល ព្រះរាជអាជ្ញា និងចៅក្រមគឺជាយុទ្ធសាស្ត្រសំខាន់ក្នុងការសាងមូលដ្ឋានគ្រឹះបម្រើឱ្យកិច្ចប្រតិបត្តិការ ហើយប្រសិទ្ធភាពក្នុងការអនុវត្តនីតិវិធីប្រតិបត្តិ ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សត្រូវបានកើនឡើង ។

-ការហ្វឹកហ្វឺននេះបានធ្វើអោយសមត្ថកិច្ចយល់ដឹង និងមានសមត្ថភាពក្នុងការចាត់វិធានការតាមនីតិវិធី ។

-ការហ្វឹកហ្វឺននេះ បានធ្វើអោយកិច្ចដំណើរការអនុវត្តនីតិវិធីមានលក្ខណៈស៊ីសង្វាក់គ្នារវាងនគរបាលព្រះរាជអាជ្ញា និងចៅក្រម ហើយមានទស្សនៈឯកភាពគ្នាលើការយល់ដឹងពីការប្រមូលផ្តុំព័ត៌មាន និងវត្ថុតាងដើម្បីដាក់បន្ទុកលើជនល្មើស ។

-ការហ្វឹកហ្វឺនស៊ីជំរៅបច្ចេកទេសស៊ើបអង្កេតដល់នគរបាល ព្រះរាជអាជ្ញា និងចៅក្រម ដែលបានអនុវត្តជំហានដំបូងនៅទីក្រុងភ្នំពេញទទួលបានលទ្ធផលល្អប្រសើរ ហើយបទពិសោធន៍នេះក៏ត្រូវបានបន្តអនុវត្តទៅខេត្ត-ក្រុងចំនួន ១១ទៀត ដោយបានបើកវគ្គសិក្សាចំនួន ០២វគ្គ មានសិក្ខាកាមសរុបចំនួន ៦០នាក់ ។

● ទន្ទឹមនឹងមានឥទ្ធិពលទៅលើអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ វិធានការយុទ្ធសាស្ត្រ ០៣ជំហានខាងលើ បានធ្វើឱ្យមន្ត្រីអនុវត្តច្បាប់មានការយល់ដឹងបានស៊ីជម្រៅពីស្ថានភាពរបស់ជនរងគ្រោះ ដែលទាម-ទារអោយមានការសង្គ្រោះ និងស្តារនីតិសម្បទាឡើងវិញ ។

ក្នុងឆ្នាំ (២០០៤-២០០៥) ក្មេងស្រីរងគ្រោះអំពីការជួញដូរផ្លូវភេទ ត្រូវបានជួយរំដោះមាន ចំនួន ៦៥៦ នាក់ បានទទួលស្ត្រីរងគ្រោះពីប្រទេសថៃដោយការជួញដូរពលកម្មចំនួន ៣៦៩នាក់ និងស្ត្រីងាយរងគ្រោះចំនួន ១៨៩ នាក់ និងបានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយការជួញដូរផ្លូវភេទ និងសុំទានពីប្រទេសវៀតណាមសរុបចំនួន ១.៩៦៩ នាក់ ។

**<u>ចំពោះការស្តារនីតិសម្បទាជនរងគ្រោះនៃអំពើជួញដូរមនុស្សរួមមាន</u> :**

-ការអប់រំ ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ដល់ជនរងគ្រោះទាំងនោះ អាចមានមុខរបរច្បាស់លាស់នៅក្នុងសង្គម សម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃដោយខ្លួនឯង ដូចជា ការបណ្តុះបណ្តាលកាត់ដេរ អ៊ុតសក់ សំអាង និង វិជ្ជាធ្វើម្ហូបជាដើម... ។ល ។

-ធ្វើការអប់រំអំពីសុខភាពបន្តពូជ អំពីបញ្ហាទាក់ទង និងជំងឺអេដស៍ និងផ្តល់ការថែទាំផ្នែកសុខភាព ។

-អប់រំបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស ពិសេសអំពីសិទ្ធិស្ត្រី និងកុមារ ។

សកម្មភាពទាំងនេះត្រូវបានរៀបចំឡើងដោយមានការសហការរវាងក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតដូចជា អង្គការ AFESIP , អង្គការ IOM , UNICEF និងអង្គការខ្មែរជួយស្ត្រីមានវិបត្តិ ... ។ល ។

## II- <u>*សកម្មភាពនៃការប្រមូលព័ត៌មានស្តីពីការជួញដូរមនុស្សនៅកម្ពុជា*</u> :

ក្រសួងមហាផ្ទៃបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដោយដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រមូលព័ត៌មាន ស្តីពីការជួញដូរមនុស្សដែលមានដូចខាងក្រោម :

-បង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ( តាមអនុក្រឹត្យលេខ ៤០អ.ក.ក្រ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ ) ដែលមាន ០៥ ការិយាល័យជំនាញ ចំណុះអោយនាយកដ្ឋាន។

-បង្កើតអោយមានការិយាល័យជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំណុះអោយស្នងការដ្ឋាននគរបាលចំនួន១៧ខេត្ត-ក្រុង និងរៀបចំជាផ្នែកជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចំណុះអោយស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ចំនួន ០៧ទៀត។

-បង្កើតប្រព័ន្ធទូរស័ព្ទពិសេស (Hot-line) ចំនួន ០២ គឺ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ០១កន្លែង និងនៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប ០១កន្លែង ដោយប្រចាំការ ២៤ម៉ោងលើ ២៤ម៉ោង ដើម្បីរង់ចាំទទួលបណ្តឹងបន្ទាន់តាមរយៈទូរស័ព្ទ។

-រៀបចំអោយមានមន្ត្រីប្រចាំការទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ។

-រៀបចំភ្នាក់ងារស៊ើបអង្កេតជាចំហរ និងសម្ងាត់ដើម្បីប្រមូលព័ត៌មាន។

● ក្នុងរយៈពេលពីរឆ្នាំ (២០០៤-២០០៥) នគរបាលបានទទួលបណ្តឹងតាមរយៈទូរស័ព្ទ និងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋសរុបចំនួន **៨១២ករណី** ក្នុងនោះសមត្ថកិច្ចនគរបាលបានធ្វើការស៊ើបអង្កេត និងបង្រ្កាបបានចំនួន **៧៧៣ករណី** រំដោះជនរងគ្រោះសរុបចំនួន **១.៣៨១នាក់** (១៨ឆ្នាំឡើងចំនួន ៨៩០នាក់ និងក្រោមអាយុ ១៨ឆ្នាំចំនួន ៤៩១នាក់) ព្រមទាំងចាប់ឃាត់ខ្លួនជនល្មើសសរុបចំនួន **៨៣២នាក់** បញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។

**សំណួរទី១៣ : អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី មូលហេតុ និងផលវិបាកបានទទួលរបាយការណ៍ដែលបង្ហាញអោយឃើញថា ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយសារការជួញដូរត្រូវបានគេចាត់ទុកថាជាជនខុសច្បាប់ ព្រោះរំលោភនឹងច្បាប់អន្តោប្រវេសន៍ ដូច្នេះគឺពុំត្រូវបានគេចាត់ទុកថា ជាជនរងគ្រោះទេ ដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភ (** E/CN/2003/75/Add.1 **កថាខណ្ឌទី៩៤៩ )។ សូមបញ្ជាក់ថាតើនៅក្នុងច្បាប់ជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ មានចែងអំពីវិធានការ ផ្តល់កិច្ចការពារដល់ស្ត្រីរងគ្រោះដោយសារការជួញដូរធ្វើជាសាក្សីឬទេ ហើយថាតើបានចាត់វិធានការជំហានអ្វីខ្លះ ដើម្បីធានាថាស្ត្រីរងគ្រោះពុំត្រូវទទួលការរងគ្រោះជាថ្មីទៀត ដោយសារប្រពន្ធ័យុត្តិធម៌ផ្នែកព្រហ្មទណ្ឌ។**

**ចម្លើយ :**

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា រួមទាំងច្បាប់ប្រឆាំងការជួញដូរមនុស្សពុំមានបញ្ញត្តិណាមួយសម្រាប់ផ្តន្ទាទោសជនរងគ្រោះដោយអំពើជួញដូរមនុស្សទេ។ របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីដែលបានលើកឡើងអំពីបញ្ហានេះអាចនឹងមានបញ្ហាមិនច្បាស់លាស់ខ្លះ ហើយក៏ប្រហែលជាចង់សំដៅលើនារីជនជាតិវៀតណាមចំនួន១៤នាក់ ដែលរំដោះចេញពីផ្ទះបន ហើយត្រូវតុលាការក្រុងភ្នំពេញ

ផ្តន្ទាទោស ពីបទឆ្លងដែនខុសច្បាប់តាមច្បាប់អន្តោប្រវេសន៍។ ដើម្បីធ្វើការពិចារណាថា តើនារីជនជាតិវៀតណាមទាំងនោះជាជនរងគ្រោះដោយអំពើជួញដូរ ឬក៏ជាជនល្មើសនឹងច្បាប់អន្តោប្រវេសន៍ បើស្ថិតនៅក្នុងករណីនេះមែន យើងសូមធ្វើការអធិប្បាយខ្លះពីអង្គហេតុ ដើម្បីមានមូលដ្ឋានសម្រាប់ធ្វើការពិចារណា។

នគរបាលមានសមត្ថកិច្ចបានរំដោះនារីទាំងនោះពីផ្ទះបន ក្នុងគោលបំណងជួយសង្គ្រោះនារីទាំងនោះឱ្យរួចផុតពីការកេងប្រវ័ញ្ចផ្លូវភេទ ដែលពេលនោះមជ្ឈដ្ឋានជុំវិញព្រមទាំងនគរបាលផង សុទ្ធតែចាត់ទុកនារីទាំងនោះជាជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ។ ប៉ុន្តែគួរឱ្យសោកស្តាយ នារីទាំងនោះបានឆ្លើយនៅចំពោះមុខអាជ្ញាធរ និងតុលាការមានសមត្ថកិច្ចថា ពួកនាង១ពុំត្រូវបានគេជួញដូរពីប្រទេសវៀតណាមមកនោះទេ គឺពួកនាងបានមកប្រទេសកម្ពុជាជាមួយឪពុក ម្តាយ ជីដូន និងបងប្អូន ឆ្លងកាត់ព្រំដែនតាមច្រករបៀងលួចលាក់ដោយគ្មានលិខិតស្នាមជាផ្លូវការទេ។ ពេលមកដល់ក្រុងភ្នំពេញ ក៏បានស្ម័គ្រចិត្តចូលរកស៊ីនៅក្នុងផ្ទះបន បំរើផ្លូវភេទដោយខ្លួនឯងដើម្បីរកប្រាក់កម្រៃ ។

ករណីបែបនេះសួរថា តើនារីទាំងនោះជាជនរងគ្រោះដោយអំពើជួញដូរមនុស្សឬយ៉ាងណា? នៅប្រទេសកម្ពុជា អ្នកស្ម័គ្រចិត្តធ្វើជាស្រីពេស្យាគឺច្បាប់ពុំបានផ្តន្ទាទោសទេ គឺច្បាប់ផ្តន្ទាទោសតែមេបនពេស្យាតែប៉ុណ្ណោះ ។

ដូច្នេះនារីទាំងនោះ ពុំបានជាប់ចោទពីបទធ្វើស្រីពេស្យាទេ។ ប៉ុន្តែករណីដែលពុំអាចរួចផុតពីការចោទប្រកាន់នោះ គឺការលួចឆ្លងកាត់ព្រំដែនចូលមកប្រទេសកម្ពុជាដោយគ្មានលិខិតស្នាមផ្លូវការ ដែលជាករណីផ្ទុយពីច្បាប់អន្តោប្រវេសន៍។ ដូច្នេះថាតើ គួរចាត់ទុកនារីជនជាតិវៀតណាមទាំងនេះ គប្បីត្រូវប្រឈមមុខនឹងច្បាប់អន្តោប្រវេសន៍ដែរឬទេ ?

នៅក្នុងច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅកម្ពុជា ពុំមានបញ្ញត្តិចែងអំពីវិធានការការពារដល់ស្ត្រីរងគ្រោះជាសាក្សីនោះទេ ព្រោះថាកិច្ចការពារសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ គឺបានកំណត់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌដែលនឹងត្រូវផ្តន្ទាទោសដល់អ្នកដែលបំពារបំពានលើសាក្សីនៃរឿងក្តី។

កិច្ចការពារជនរងគ្រោះក្នុងអំពើជួញដូរមនុស្សសំរាប់ធ្វើជាសាក្សី គឺបានធ្វើឡើងជាការណែនាំដល់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធជាពិសេសនគរបាលមានសមត្ថកិច្ចនៅតាមវគ្គសិក្សានានា ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស។

វិធានការដើម្បីធានាថា ស្ត្រីរងគ្រោះពុំត្រូវបានរងគ្រោះបន្ថែមទៀតដោយសារតែប្រព័ន្ធយុត្តិធម៌ព្រហ្ម-ទណ្ឌនោះគឺ :

- ច្បាប់មិនបានចាត់ទុកជនរងគ្រោះដោយអំពើជួញដូរថាជាជនល្មើសនោះទេ។ ដូច្នេះជនទាំងនេះពុំត្រូវបានដាក់នៅក្នុងកន្លែងឃុំឃាំងនោះឡើយ ។

- បានបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដូចជា នគរបាល ព្រះរាជអាជ្ញា និងចៅក្រមឱ្យយល់ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដាច់ចេញពីជនអន្តោប្រវេសន៍ខុសច្បាប់ និងក្នុងអំពើរត់ពន្ធមនុស្ស។

## មាត្រា ៧

**សំណួរទី១៤ : របាយការណ៍ បានឆ្លុះបញ្ចាំងអំពីការអនុវត្តសកម្មភាពមួយចំនួន ក្នុងគោលបំណងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយ និងការងារវិស័យសាធារណៈនៅគ្រប់កំរិត (ទំព័រទី៤០)។ សូមផ្តល់ព័ត៌មានអំពីការរីកចំរើនក្នុងការអនុវត្តសកម្មភាពទាំងនេះ រួមទាំងឥទ្ធិពលនៃគោលនយោបាយទាំងនេះ?**

**ចម្លើយ :**

ការរីកចម្រើនក្នុងការអនុវត្តសកម្មភាពកន្លងមកនេះ រាជរដ្ឋាភិបាលបាននឹងកំពុងខិតខំប្រឹងប្រែងជំរុញឱ្យស្ត្រីចូលរួមកាន់តែច្រើនថែមទៀត ទាំងក្នុងជីវភាពនយោបាយ និងវិស័យសាធារណៈ ដែលមានជាអាទិ៍ដូចជា :

**ក-** ការអនុវត្តគោលនយោបាយបញ្ជ្រាបយេនឌ័រនៅតាមក្រសួងនានា ហើយក្រសួងពាក់ព័ន្ធទាំងនោះក៏បាននឹងកំពុងរៀបចំយុទ្ធសាស្ត្រយេនឌ័រ របស់ខ្លួនផងដែរ។ ទន្ទឹមនឹងនេះក៏មានក្រសួងមួយចំនួនបានត្រូវការជំនួយបច្ចេកទេសរួមមាន ក្រសួងព័ត៌មាន ក្រសួងសុខាភិបាល និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ករណីនេះ ក្រសួងកិច្ចការនារី ដោយមានការសហការគ្នាជាមួយអង្គការ UNDP បានបញ្ជូនទីប្រឹក្សាជាតិខ្មែរខាងយេនឌ័រ ដើម្បីជួយរៀបចំយុទ្ធសាស្ត្រនេះ។

**ខ-** ការរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលអំពីយេនឌ័រ និងការអភិវឌ្ឍន៍ យើងបានរៀបចំឱ្យមានការបណ្តុះបណ្តាលពីរបែបគឺ :

**ខ-១ :** ការបណ្តុះបណ្តាលនៅតាមក្រសួង និងស្ថាប័ននានា : ក្រសួងកិច្ចការនារី បានតស៊ូមតិ និងស្នើឱ្យមានការបង្កើតជនបង្គោលយេនឌ័រនៅតាមក្រសួង ស្ថាប័ននានា ដែលរហូតមកដល់បច្ចុប្បន្ននេះមានជនបង្គោលរួចហើយ។ជនបង្គោលទាំងនោះសុទ្ធតែបានទទួលការបណ្តុះបណ្តាល អំពីយេនឌ័រ និងការអភិវឌ្ឍន៍។ លើសពីនេះ ក្រសួងកិច្ចការនារី កំពុងសហការជាមួយជនបង្គោលទាំងនោះ ព្រមទាំងមានការចូលរួមរបស់ NGO មួយចំនួនក្នុងការផ្សព្វផ្សាយអំពីយេនឌ័រនៅតាមក្រសួង ស្ថាប័នរបស់ជនបង្គោលទាំងនោះ ដែលមាន១ វឺ ២វគ្គ សម្រាប់ក្រសួងស្ថាប័ននីមួយៗ ហើយក្នុងមួយវគ្គៗមានពី ៣ ទៅ ៤ ថ្ងៃ ។ រីឯការផ្សព្វផ្សាយអំពីយេនឌ័រដល់សមាជិកសភា គឺក្រសួងកិច្ចការនារី បានរៀបចំក្នុងទម្រង់ជាការអញ្ជើញ ឥស្សរៈជនទាំងនោះ មកពិភាក្សាអំពីយេនឌ័រ។

**ខ-២ :** ការផ្សព្វផ្សាយអំពីយេនឌ័រ និងការអភិវឌ្ឍន៍ដល់មូលដ្ឋាន និងជនបទ : ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានសហការមួយកម្មវិធីសីលា (ដែលជាកម្មវិធីអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន) បានមកចុះទៅផ្សព្វផ្សាយនៅតាមមូលដ្ឋានថ្នាក់ឃុំ សង្កាត់ នៅគ្រប់ទូទាំងខេត្ត ក្រុង នៃព្រះរាជាណាចក្រ-កម្ពុជា ។

**គ -** ក្រសួងកិច្ចការនារី បានបញ្ចូលទៅក្នុងអភិបាលកិច្ចរបស់រាជរដ្ឋាភិបាលលើកទី ២ – GAP II ( ២០០៤ -២០០៥ ) នូវស្ត្រីជាមន្ត្រីរាជការចំនួន ៣០% ក្នុងចំណោមមន្ត្រីរាជការទាំងអស់។

**ឃ -** ក្រសួងកិច្ចការនារីក៏បានរៀបចំកម្មវិធីផងដែរនៅក្នុងកម្មវិធីតស៊ូមតិ ដើម្បីឱ្យគណបក្សនយោ-បាយនីមួយៗដាក់បេក្ខនារីនៅលំដាប់ថ្នាក់ខ្ពស់ ក្នុងបញ្ជីបេក្ខភាពសំរាប់ការបោះឆ្នោតនានា។ តាមរយៈនេះ

ពិនិត្យឃើញថា ចំនួនតួលេខបេក្ខនារីជាប់ឆ្នោតមានការកើនឡើង ដូចមានបង្ហាញនៅក្នុងតារាង "ឥទ្ធិពលនៃនយោបាយ" ដូចខាងក្រោម ៖

**<u>តារាងបង្ហាញអំពីកំណើនតួលេខនៃការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយ និងវិស័យសាធារណៈ</u>**

| **សមាសភាពស្ត្រីជា** | **អាណត្តិទី២ (១៩៩៨-២០០៣)** | | **អាណត្តិទី៣ (២០០៣-២០០៨)** | | **ចំនួនតួលេខកើន** |
|---|---|---|---|---|---|
| | **ចំនួនសរុប** | **ចំនួនស្ត្រី** | **ចំនួនសរុប** | **ចំនួនស្ត្រី** | |
| **ក្រុមខំណួនយោបាយ** | | | | | |
| សមាជិកព្រឹទ្ធសភា | ៦១ នាក់ | ០៨ នាក់ | ៦១ នាក់ | ១១ នាក់ | ០៣ នាក់ |
| សមាជិករដ្ឋសភា | ១២២ នាក់ | ១៤ នាក់ | ១២៣ នាក់ | ២២ នាក់ | ០៨ នាក់ |
| សមាជិករាជរដ្ឋាភិបាល | ២០៤ នាក់ | ១០ នាក់ | ៣១៦ នាក់ | ២៤ នាក់ | ១៤ នាក់ |
| អនុរដ្ឋលេខាធិការ | | | ១៤៦ នាក់ | ១៤ នាក់ | ១៤ នាក់ |
| **វិស័យសាធារណៈ** | | | | | |
| ឧត្តមសេនីយ៍ | | ០៣ នាក់ | | ០៣ នាក់ | ០៣ នាក់ |
| អភិបាលរងខេត្ត ក្រុង | | ០១ នាក់ | ១៨០ នាក់ | ០៣ នាក់ | ០២ នាក់ |
| អគ្គនាយក | | | ៧៦ នាក់ | ០២ នាក់ | ០២ នាក់ |
| អគ្គនាយករង | | | ១៣៦ នាក់ | ១៥ នាក់ | ១៥ នាក់ |
| ប្រធាននាយកដ្ឋាន | | | ៣១៤ នាក់ | ២៧ នាក់ | ២៧ នាក់ |
| អភិបាលរងស្រុក ខ័ណ្ឌ | | | ៩៤៤ នាក់ | ១៤ នាក់ | ១១ នាក់ |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | | | ១១.២៦១ នាក់ | ៩៨៣ នាក់ | ៩៨៣ នាក់ |
| ស្មៀនឃុំ សង្កាត់ | | | ១.៩១១ នាក់ | ១៧៨ នាក់ | ០០ នាក់ |

## មាត្រា ៩

**សំណួរទី១៥ ៖ របាយការណ៍បានចែងថា "កូនដែលកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបានសញ្ជាតិខ្មែររួមមាន ៖ កូនដែលកើតពីឪពុក ឬម្ដាយបរទេសដែលកើតនិងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកូនដែលកើតពីឪពុកម្ដាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា" (ទំព័រទី៤៣)។ សូមផ្ដល់ព័ត៌មានបញ្ជាក់ ថាតើច្បាប់នេះត្រូវបានពង្រឹងនិងអនុវត្តទេ? ជាពិសេសតើស្ត្រីជនជាតិវៀតណាម ស្ត្រីជនជាតិភាគតិច និងស្ត្រីក្រីក្រមានលទ្ធភាពអាចទទួលបានសញ្ជាតិ ហើយថាតើសិទ្ធិរបស់ពួកគេត្រូវបានគេគោរពទេ ទាំងនៅក្នុងច្បាប់ និងការអនុវត្តជាក់ស្ដែងទេ?**

**ចម្លើយ ៖**

ចាប់តាំងពីច្បាប់ ស្តីពីសញ្ជាតិ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៦ មក រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់អនុវត្តយ៉ាងខ្ជាប់ខ្ជួន និងកំពុងពង្រឹងការអនុវត្តយ៉ាងសកម្ម ដើម្បីធានាការផ្តល់សញ្ជាតិខ្មែរស្របច្បាប់អោយដល់ប្រជាពលរដ្ឋខ្មែរ។

ចំពោះស្ត្រីជនជាតិភាគតិច ស្ត្រីក្រីក្រ និងជនជាតិវៀតណាម សុទ្ធតែមានលទ្ធភាពអាចទទួលបានសញ្ជាតិខ្មែរទាំងអស់ ឱ្យតែជននោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានបំពេញតាមលក្ខខ័ណ្ឌនៃច្បាប់សញ្ជាតិជាមួយនោះ សិទ្ធិរបស់ពួកគេត្រូវបានគេគោរពទាំងនៅក្នុងច្បាប់ និងក្រៅច្បាប់។

## មាត្រា ១០

**សំណួរទី១៦ ៖ របាយការណ៍បានបង្ហាញអោយឃើញថាបញ្ហាអនក្ខរភាព ដែលជាបញ្ហាប៉ះពាល់យ៉ាងខ្លាំងលើស្ត្រី ប៉ុន្តែពុំត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្ររបស់ ក្រសួងអប់រំ យុវជន និងកីឡា ឡើយ។ ដូច្នេះសូមផ្តល់ព័ត៌មានអំពីជំហានដែលកំពុងធ្វើផែនការ ឬអនុវត្ត ដើម្បីដោះស្រាយបញ្ហាអត្រាអនក្ខរភាពខ្ពស់ក្នុងចំណោមស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីនៅជនបទ និងស្ត្រីជនជាតិភាគតិច?**

**ចម្លើយ ៖**

ទោះជាក្នុងរបាយការណ៍មុន ក្រសួងអប់រំ យុវជន និង កីឡា ពុំទាន់បានបញ្ចូលយុទ្ធសាស្ត្រ ស្តីពីអនក្ខរភាពនេះក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និង កីឡា តែមួយប៉ុណ្ណោះ បានរៀបចំដោះស្រាយចាប់ពីឆ្នាំ២០០០ ដូចខាងក្រោម ÷

បញ្ហាអត្រាអនក្ខរភាពខ្ពស់នេះបានដំណើរការកម្មវិធី សមមូលតាមរយៈ កម្មវិធីអក្ខរកម្មបំពេញវិជ្ជា កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈការកសាង និងដំណើរការមជ្ឈមណ្ឌលសិក្សា សហគមន៍ ការបង្កើតសាលា ឬថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈឯកជន កម្មវិធីកែលំអគុណភាពបំណិនជីវិត និងការផ្សព្វផ្សាយកម្មវិធីអប់រំគ្រួសារ ដើម្បីអភិវឌ្ឍគាំពារកុមារតូចលើមុខសញ្ញាសិស្ស បំពេញវិជ្ជាគ្រប់ភូមិសិក្សាដែលមានចំនួនសរុប ១.៨២៦នាក់ ក្នុងនោះមានសិស្សស្រី ៣៧១ នាក់ មុខសញ្ញាអនក្ខរជន អាយុពី ១៥-៤៥ ឆ្នាំ ដែលមានចំនួនសរុប ៤៨៦៩៥ នាក់ ស្រី ៣២៣៣៥នាក់ មុខសញ្ញាកុមារក្រៅសាលាសរុប ៤.៨៥៨នាក់ ស្រី ២.៦៨៧នាក់ និងមុខសញ្ញាផ្សេងៗទៀតដោយរំដោះបានពីអនក្ខរភាពចំនួនសរុប ៧៦.៦១៩នាក់ ស្រី ៥៣.០៨៥នាក់ (តួលេខក្រសួងអប់រំ យុវជន និងកីឡា)។ លើកម្មវិធីអប់រំអក្ខរកម្ម ក្រសួងអប់រំ យុវជន និង កីឡា បានអនុវត្តកម្មវិធីអប់រំអក្ខរកម្មដល់មុខសញ្ញាទាំងពីរភេទ ដោយមានការកសាងបណ្ណាល័យ មណ្ឌលអាន បណ្ណាល័យចល័តនៅតាមខេត្តមួយចំនួន ដូចជា កំពង់ធំ សៀមរាប ឧត្តរមានជ័យ រតនគីរី កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ក្រចេះ។ ក្រៅពីការឧបត្ថម្ភដោយរដ្ឋាភិបាល ការងារអប់រំអក្ខរកម្មនៅ មានការចូលរួមពីអង្គការនានាជាច្រើន។

ដើម្បីដោះស្រាយបញ្ហាអត្រាអនក្ខរភាពខ្ពស់ក្នុងចំណោមស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីនៅជនបទ និងស្ត្រីជនជាតិភាគតិច ក្រសួងអប់រំ យុវជន និងកីឡា និងអគ្គលេខាធិការដ្ឋានអប់រំសម្រាប់ទាំងអស់គ្នាមានផែនការអនុវត្តសម្រាប់ឆ្នាំ២០០៦ ដល់ ឆ្នាំ២០១០ :

-ចុះស្រាវជ្រាវ ស្រង់ស្ថិតិស្ត្រីជាអនក្ខរជនតាមតំបន់ (ទីក្រុង ជនបទដាច់ស្រយាល) នៅទូទាំងប្រទេស។

-កសាងបន្ថែមមជ្ឈមណ្ឌលសិក្សាសហគមន៍ មណ្ឌលអាន បណ្ណាល័យ បណ្ណាល័យចល័តឱ្យបានដល់តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។

-ពិនិត្យ និងកែលំអកម្មវិធីសិក្សា និងសៀវភៅសិក្សាអក្ខរកម្មឡើងវិញ ដោយមានបញ្ជ្រាបការអប់រំយេនឌ័រ សិទ្ធិស្ត្រី សិទ្ធិកុមារ ការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងស្ត្រីភេទ ការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ការកំចាត់គ្រឿងញៀន ការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ឱ្យស្របតាមវប្បធម៌ប្រពៃណីជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងចម្លើយតបទៅនឹងសំណួរទី៩ខាងលើ។

-ដំណើរការកម្មវិធីអក្ខរកម្មផ្សារភ្ជាប់នឹងវិជ្ជាជីវៈងាយៗ និងបំណិនជីវិតដល់ស្ត្រីនិងសិស្សអក្ខរកម្ម។

**សំណួរទី១៧ : របាយការណ៍បានបង្ហាញថា ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទំរង់កម្មវិធីសិក្សានៅមត្តេយ្យសិក្សា និងថ្នាក់មធ្យមសិក្សាទៅតាមស្តង់ដារអន្តរជាតិ (ទំព័រទី៥០)។ ដូច្នេះសូមផ្តល់ព័ត៌មាន ថាតើកំណែទំរង់នេះ បានចូលរួមចំណែកក្នុងការលុបបំបាត់ទស្សនៈខុសឆ្គងអំពីតួនាទីរបស់ស្ត្រី និងបុរស ដែលមាននៅក្នុងសៀវភៅ និងកម្មវិធីសិក្សា ហើយសូមផ្តល់ព័ត៌មានផងដែរ ថាតើកំណែទំរង់នេះនឹងធ្វើនៅក្នុងថ្នាក់បឋមសិក្សា និងថ្នាក់ឧត្តមសិក្សាដែរឬទេ?**

**ចម្លើយ :**

នៅឆ្នាំសិក្សា ២០០៤-២០០៥ ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការកែលំអកម្មវិធីសិក្សានៅមត្តេយ្យសិក្សាដោយបានបញ្ចូលខ្លឹមសារអប់រំដើម្បីអភិវឌ្ឍន៍រូបរាងកាយ បញ្ញាស្មារតី និងចិត្តសង្គម និងការបញ្ជ្រាបយេនឌ័រ ដើម្បីធានាបានការអប់រំដោយពុំមានការរើសអើងភេទ។

កម្មវិធីសិក្សាបឋមសិក្សា និងមធ្យមសិក្សា បានបញ្ចូលការអប់រំគេហកិច្ច ដែលមានលើកឡើងពីតួនាទីរបស់បុត្រទាំងពីរភេទ ក្នុងការជួយកិច្ចការគ្រួសារ ទាំងការដាំស្ល ថែទាំប្អូន ដេរប៉ាក់ ថែទាំផ្ទះសម្បែងទាំងការចូលរួមក្នុងការកសាងផែនការ គ្រួសារ ការអប់រំបំណិនជីវិតជាដើម។

កម្មវិធីសិក្សាក៏រិតឧត្តមសិក្សា បានលើកឡើងពីការបណ្តុះបណ្តាលឯកទេសជំនាញ ដោយពុំមានការបែងចែកមុខជំនាញវិជ្ជាជីវៈសម្រាប់បុរសដោយឡែកពីស្ត្រីឡើយ។ ក្នុងការបង្កើតក្លឹបសិក្សា ឬចុះធ្វើកម្មសិក្សាប្រតិបត្តិ ត្រូវមានចម្រុះនិស្សិតទាំងពីរភេទ ។

ក្នុងរចនាសម្ព័ន្ធ កម្មវិធីសិក្សាមានបញ្ច្រាប និងបញ្ចូលសិទ្ធិមនុស្ស សិទ្ធិស្ត្រី ការអប់រំសុខភាព ការទប់ស្កាត់ជម្ងឺអេសដ៍ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទ ការជួញដូរពលកម្មកុមារ និងស្ត្រី ការប្រព្រឹត្តគ្រឿងញៀន... ច្បាប់ផ្សេងៗទៅតាមមុខវិជ្ជា និងផ្នែកនីមួយៗ។ ក្នុងការអនុវត្តការបង្រៀនមេរៀនតាមមុខវិជ្ជានីមួយៗក៏មានការបញ្ច្រាបការអប់រំយេនឌ័រ ផ្អែកលើខ្លឹមសារដែលទទួលបានពីការបំប៉នរបស់អង្គការក្រៅរដ្ឋាភិបាល។

**សំណួរទី១៨ : សូមផ្តល់ព័ត៌មានបន្ថែម ស្តីពីកម្រិតនៃការសិក្សា និងការទទួលបានការសិក្សារបស់ក្មេងស្រី និងស្ត្រីវ័យក្មេង ដែលជាជនជាតិភាគតិចមកពីតំបន់ជនបទ និងជាប្រជាជនក្រីក្រ។ សូមផ្តល់ព័ត៌មានផងដែរ ថាតើក្មេងស្រីទាំងនេះ ជាក្រុមគោលដៅពិសេសនៅក្នុងផែនការសកម្មភាពជាយុទ្ធសាស្ត្រសំរាប់ ឆ្នាំ២០០២-០៦ របស់ ក្រសួងអប់រំ យុវជន និងកីឡា ទេ?**

**ចម្លើយ :**

ក្មេងស្រី និងស្ត្រីវ័យក្មេងដែលជាជនជាតិភាគតិចមកពីតំបន់ជនបទ និងជាប្រជាជនក្រីក្រ បានទទួលការសិក្សាគ្រប់កំរិត។ ក្មេងស្រីទាំងនេះជាក្រុមគោលដៅពិសេសនៅក្នុងផែនការសកម្មភាពជាយុទ្ធសាស្ត្រ សម្រាប់ឆ្នាំ ២០០២- ២០០៦ របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលមានដូចតទៅ :

-ការអនុវត្តវិមជ្ឈការកាលវិភាគ ។

-ការផ្តល់អាទិភាពដល់ការជ្រើសរើសធនធានសិស្សស្រីដែលមានស្រាប់ នៅតំបន់ជនជាតិភាគតិចមកពីតំបន់ក្រីក្រ និងតំបន់ជនបទឱ្យធ្វើគ្រូដើម្បីអាចធានាបានការសិក្សា និងការទទួលបានការសិក្សា។

-ការរៀបចំសាលារៀនឱ្យក្លាយទៅជាសាលាកុមារមេត្រី។

-ការអនុវត្តការបង្រៀនថ្នាក់គួប និងការផ្តល់អាហារសម្រន់នៅតាមសាលារៀនដែលស្ថិតនៅក្នុងតំបន់ក្រីក្រ។

ចំពោះសាលាដែលមិនមានគ្រប់កម្រិតក្រសួងអប់រំ យុវជន និង កីឡា បានសាងសង់សាលារៀនថ្មី និងបន្ទប់រៀនថ្មីនៅតំបន់ដែលមានការខ្វះខាត បានសាងសង់ផ្ទះស្នាក់នៅសម្រាប់គ្រូដែលបំរើការនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។

**សំណួរទី១៩ : សូមផ្តល់ព័ត៌មានអំពីយុទ្ធសាស្ត្រដែលបានគ្រោង ដើម្បីដោះស្រាយចំពោះមូលហេតុដែលក្មេងស្រីបោះបង់ចោលសាលារៀន។ ជាពិសេសសូមផ្តល់ព័ត៌មានពិស្តារអំពីរយៈពេល និងធនធានសំរាប់ការអនុវត្តយុទ្ធសាស្ត្រទៅអនាគតដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងក្មេងស្រី នៅក្នុងវិស័យអប់រំដូចដែលបានរៀបរាប់នៅក្នុងទំព័រទី៥៤-៥៦ ហើយសូមផ្តល់ព័ត៌មានអំពីកម្មវិធីជាក់លាក់ដែលមានសម្រាប់ស្ត្រីក្រីក្រ ស្ត្រីជនបទ និងស្ត្រីជនជាតិភាគតិច។**

**ចម្លើយ ៖**

ដើម្បីដោះស្រាយមូលហេតុដែលក្មេងស្រីបោះបង់ការសិក្សា ក្រសួងអប់រំ យុវជន និង កីឡា និងអង្គការអន្តរជាតិ ជាដៃគូបានផ្តល់អាហារូបករណ៍ និងអាហារូបត្ថម្ភដល់សិស្សក្រីក្រ ផ្តល់សៀវភៅគ្រូឱ្យបានគ្រប់កម្រិតនៃការអប់រំមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាពិសេសមេភូមិ គឺជាកម្លាំងដែលជួយក្នុងការជំរុញមាតាបិតាឱ្យបញ្ជូនកូនទៅរៀនបន្ត និងបញ្ចប់ការសិក្សា។ ក្រសួងអប់រំ យុវជន និង កីឡា បន្តលុបបំបាត់ការចំណាយក្រៅផ្លូវការរបស់ឪពុកម្តាយសិស្សតាមរយៈការផ្តល់ ថវិកាដំណើរការសាលារៀន។ ការបង្កើតក្រុមសិស្សតាមភូមិ ការរីកមុខរកជនប្រព្រឹត្តអំពើជួញដូរផ្លូវភេទ ជួញដូរពលកម្ម កុមារ ជនចាប់រំលោភផ្លូវភេទ គឺជាតួនាទីរបស់ក្រុម ប្រឹក្សាឃុំ សង្កាត់ ដែលបានអនុវត្តកន្លងមក ដើម្បីសុខសុវត្ថិភាពសិស្សស្រីទៅសាលា និងត្រឡប់មកផ្ទះនៅតំបន់គោលដៅ (តំបន់ដាច់ស្រយាល តំបន់ជនបទ និងជនជាតិភាគតិច) ។ ការជួយលើក ទឹកចិត្តសិស្សស្រីដែលរៀនខ្សោយតាមរយៈការបំប៉នស្របពេលសិក្សា។ ក្រសួងអប់រំយុវជន និង កីឡា បានកសាងអន្តេវាសិកដ្ឋានបានមួយចំនួននៅតំបន់ដាច់ស្រយាលសម្រាប់សិស្សស្រីក្រីក្រ (មាននៅក្នុងមាត្រា ៤)។ ក្រុមប្រឹក្សាឃុំ សង្កាត់ សហការជាមួយមន្ទីរកសិកម្ម និងអង្គការក្រៅរដ្ឋាភិបាលបានរៀបចំផែនការ ដើម្បីធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈងាយៗ ដូចជាការដាំដុះ ការចិញ្ចឹមសត្វ ចិញ្ចឹមត្រី ដើម្បីរកប្រាក់ចំណូល និងផ្តល់នូវឥណទានខ្នាតតូចជូនដល់ប្រជាពលរដ្ឋ។

**សំណួរទី២០ ៖ សូមផ្តល់ព័ត៌មានថាតើមានការផ្សព្វផ្សាយអំពីការធ្វើផែនការគ្រួសារ និងការអប់រំអំពីភេទនៅតាមសាលាសម្រាប់ក្មេងស្រី និងក្មេងប្រុសនៅក្នុងផ្នែកមួយនៃកម្មវិធីសុខភាពឬទេ? (ទំព័រទី៥៣) ហើយបើសិនជាពុំមានទេនោះ សូមផ្តល់ព័ត៌មានថាតើការផ្សព្វផ្សាយអំពីការធ្វើផែនការគ្រួសារ និងការអប់រំអំពីភេទដល់មនុស្សវ័យក្មេងធ្វើឡើងតាមមធ្យោបាយណា?**

**ចម្លើយ ៖**

ក្នុងការផ្សព្វផ្សាយអំពីការធ្វើផែនការគ្រួសារនៅតាមសាលារៀនសម្រាប់ក្មេងស្រី និងក្មេងប្រុសគ្រូបានបង្រៀនអំពីរបៀបធ្វើ និងអនុវត្តផែនការតូចៗងាយៗ ដោយផ្អែកលើស្ថានភាពតម្រូវការធនធានលទ្ធភាពជាក់ស្តែង និងឆ្លងកាត់ការសម្រេចចិត្តរបស់គ្រួសារ និងអ្នកអនុវត្ត។ ជំហានទី១ ឱ្យសិស្សធ្វើការស្វែងយល់ស្ថានភាពជាក់ស្តែង ធ្វើវិភាគហេតុផលនៃតម្រូវការនីមួយៗ និងសម្រិតសម្រាំងសម្រេចជ្រើសរើសអាទិភាព។ ជំហានទី ២ កសាងផែនការដោយកំណត់គោលបំណងច្បាស់លាស់ ទំហំការងារ សកម្មភាព កាលបរិច្ឆេទ រយៈពេល វិធី-អនុវត្ត មធ្យោយ ដំណើរការ អ្នកទទួលខុសត្រូវ អ្នកចូលរួមធ្វើការពិនិត្យតាមដាន វាយតម្លៃ ចងក្រងឯកសារបទពិសោធធ្វើរបាយការណ៍ និងធ្វើការផ្សព្វផ្សាយ។ ជំហានទី ៣ អនុវត្តផែនការដែលបានកសាង។

ដំណើរការការងារខាងលើមានការចូលរួមពិភាក្សារវាងនាយកសាលាគ្រូ និងសហគមន៍ ការពិភាក្សារវាងគ្រូ និងសិស្ស ការពិភាក្សារវាងសិស្ស មាតាបិតា និងសមាជិកគ្រួសារដោយមានការរាយការណ៍ជូនគ្រូ និងមិត្តរួមថ្នាក់នៅរៀងរាល់ថ្ងៃព្រហស្បតិ៍។

លើការអប់រំអំពីភេទ ក្រសួងអប់រំ យុវជននិងកីឡា ដំណើរការរួមគ្នាជាមួយកម្មវិធីអប់រំHIV/AIDS កាមរោគ សុខភាព ផ្លូវភេទ គ្រឿងញៀន និងបំណិនជីវិតតាមរយៈការធ្វើសិក្ខាសាលាបណ្ដុះបណ្ដាលថ្នាក់ខេត្ត ដែលមានមុខសញ្ញា អភិបាលខេត្ត ស្រុក មន្ទីរជុំវិញខេត្ត ការិយាល័យជំនាញ និងព្រះសង្ឃចំនួន ១ថ្ងៃ។ សិក្ខា-សាលាបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ស្រុកចំនួន ៥ ថ្ងៃ គ្រូបង្រៀនថ្នាក់ទី៥ និងថ្នាក់ទី៦សម្រាប់បឋមសិក្សា ថ្នាក់ទី៩ និងថ្នាក់ទី១២ សម្រាប់មធ្យមសិក្សា យុវជន យុវតីក្រៅសាលា ចំនួន ៥ ថ្ងៃ (៣ថ្ងៃ ធ្វើការបំប៉ន និង២ថ្ងៃ ធ្វើការផ្សព្វផ្សាយ) ដើម្បីយកទៅធ្វើការផ្សព្វផ្សាយបន្ត។ នៅឆ្នាំ ២០០៦ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូនឹងធ្វើការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តរបស់កម្មវិធីទាំង ៥ ខាងលើ។

## មាត្រា ១១

**សំណួរទី២១ : របាយការណ៍ទទួលស្គាល់ថា " ការអនុវត្តច្បាប់នៅទន់ខ្សោយ ប៉ុន្តែរាជរដ្ឋាភិបាលនឹងចាត់វិធានការដើម្បីពង្រឹងការអនុវត្តច្បាប់ (ទំព័រទី៦២)។ សូមផ្ដល់ព័ត៌មានអោយបានច្បាស់អំពីវិធានការដែលកំពុងគ្រោង ដើម្បីធានាអោយបាននូវការអនុវត្តច្បាប់ និងការត្រួតពិនិត្យការអនុវត្តច្បាប់ពាក់ព័ន្ធ និងជាពិសេសមាត្រា១៧២នៃច្បាប់ការងារដែល ស្ដីអំពីការយាយីផ្លូវភេទ ក៏ដូចជាមាត្រា៤៦.២ នៃរដ្ឋធម្មនុញ្ញដែលនិយាយអំពីសិទ្ធិសំរាកមាតុភាព?**

**ចម្លើយ :**

ការអនុវត្តច្បាប់ និងបទបញ្ញត្តិ ស្ដីពីការងារដែលត្រូវបានប្រកាសអោយប្រើនាឆ្នាំ ១៩៩៧ ត្រូវបានពង្រឹងជាបន្តបន្ទាប់ ធានានូវការបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។ ក្នុងការពង្រឹងច្បាប់នេះ កន្លងមករាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើនក្នុងការដាក់ឱ្យអនុវត្តក៏ដូចជាការត្រួតពិនិត្យការអនុវត្តច្បាប់ ស្ដីពីការងារជាពិសេសត្រង់មាត្រា ១៧២ និងស្របទៅនឹងមាត្រា ៤៦.២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤៦.២ នៃរដ្ឋធម្មនុញ្ញចែងថា: **"ត្រូវហាមឃាត់មិនអោយមាន ការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយត្រូវបានទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងទៀត"**។ ការការពារមានលក្ខណៈដូចគ្នានេះ មានចែងផងដែរក្នុងច្បាប់ ស្ដីពីការងារត្រង់មាត្រា ១៨២ កឋាខណ្ឌ ទី៣: **"ការបញ្ឈប់ការងាររបស់ស្ត្រីនៅក្នុងពេលដែលស្ត្រីរូបនេះឆ្លងទន្លេ ត្រូវហាមឃាត់ដាច់ខាត "** ។

មាត្រា ១៧២ នៃច្បាប់ ស្តីពីការងារ ( ផ្នែកទី៨ នៃជំពូកទី ៦ ស្តីពីការងារសម្រាប់ក្មេង និងការងារសម្រាប់ស្ត្រី) ចែងថាៈ **នយោជក និងនាយកគ្រឹះស្ថាន ដែលមានប្រើកម្មករ ជាក្មេង ឬកូនជាង អាយុតិចជាង១៨ឆ្នាំ ឬស្ត្រីឱ្យធ្វើការក្នុងនោះ ត្រូវមើលឱ្យមានកិរិយាមាយាទល្អ ហើយនិងរក្សាការសមរម្យចំពោះសាធារណៈជន។ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង ចំពោះការរំលោភខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់** ។

**<u>ការចាត់វិធានការធានាការអនុវត្តច្បាប់</u>** :

ក្នុងអំឡុងពេលដាក់របាយការណ៍ពីលើកមុនពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៣ និងមកដល់ពេលបច្ចុប្បន្ននេះ ក្រសួងទទួលបន្ទុកវិស័យការងារបានគ្រោង និងអនុវត្តវិធានការចាំបាច់ខ្លះដូចខាងក្រោម :

- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ៥២ សកបយ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការរៀបចំបង្គន់អនាម័យ ដែលត្រូវធ្វើដាច់ដោយឡែកពីគ្នារវាងស្ត្រី និង បុរស។

- សារាចររបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ០១២ សកបយ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារ នៅតាមគ្រឹះស្ថានផលិតផលដែលជាចំណុចពិសេស ចំណុចទី ៩ នៃសារាចរនេះ មានចែងអំពីវិធានការការពារក្នុងករណីដែលមានប្រើប្រាស់កម្មករ និយោជិត ដែលមានអាយុចាប់ពី ១៥ឆ្នាំ ដល់ ១៨ឆ្នាំ។

- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ១៤៤ សកបយ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីបដិប្បញ្ញត្តិ ចំពោះការហាមឃាត់មិនប្រើក្មេងធ្វើការពេលយប់។

- ប្រកាសរបស់ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ១៤៥ សកបយ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការហ្វឹកហ្វឺន វិជ្ជាជីវៈ ដល់ក្មេងសម្រាប់ធ្វើការក្រោមដី។

- ចេញសេចក្តីជូនដំណឹងរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ១១ សកបយ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីគោលបំណងបង្កភាពងាយស្រួលដល់ការត្រួតពិនិត្យអាយុពិតប្រាកដ របស់អ្នកសុំការងារធ្វើ។

- ណែនាំគ្រឹះស្ថានឯកជននានាឱ្យអនុវត្តមាត្រា ១៨២ ដល់ ១៨៨ នៃចំណុច គ ស្តីពីការងារសម្រាប់ស្ត្រីនៃជំពូក ទី៦ នៃច្បាប់ស្តីពីការងារ ដោយតម្រូវឱ្យគ្រឹះស្ថាននីមួយៗកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងទៅតាមការងារជាក់ស្តែងនៅទីកន្លែងធ្វើការនីមួយៗ ធានាមិនប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងភាពថ្លៃថ្នូររបស់ស្ត្រីមុន និងក្រោយពេលសម្រាលកូន។

**<u>ការត្រួតពិនិត្យការអនុវត្តច្បាប់</u>** : ក្នុងការត្រួតពិនិត្យការអនុវត្តច្បាប់ និងបទបញ្ញត្តិជាធរមាន ក្រសួងទទួលបន្ទុកវិស័យការងារបាន :

- ចាត់ក្រុមចុះធ្វើអធិការកិច្ចការងារ ដើម្បីទៅពិនិត្យការអនុវត្តច្បាប់ និងបទបញ្ញត្តិជាធរមាននេះនៅតាមគ្រឹះស្ថាននានាជាប្រចាំ ក្នុងគោលបំណងកែលំអរាល់ការអនុវត្តមិនទាន់បានល្អប្រសើរ និងតម្រូវឱ្យធ្វើការកែសម្រួលជាបន្ទាន់ ចំពោះការអនុវត្តរាល់កំហុសឆ្គងធ្ងន់ធ្ងរ ដែលនាំអោយប៉ះពាល់ដល់កម្មករនិយោជិតភេទស្រ្តី និងកុមារ ។

- នៅពេលទទួលបានដំណឹង ស្តីពីការអនុវត្តនូវកំហុសឆ្គង ឬការរំលោភមាត្រានៃច្បាប់ ក្រសួងបានចាត់មន្ត្រីជំនាញទៅពិនិត្យ និងចាត់វិធានការស្របទៅតាមនីតិវិធី និងបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជា ។

- រាជរដ្ឋាភិបាលកម្ពុជា សមាគមនិយោជកកម្ពុជា និងសហពន្ធ័សហជីពនៅកម្ពុជា ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក និងអង្គការអន្តរជាតិខាងការងារ បានដំណើរការគំរោងការងារចំនួន ៣ គឺ (១) គំរោងស្តីពី ការតាមឃ្លាំមើលលក្ខខណ្ឌការងារនៅកម្ពុជា (២) គំរោងស្តីពីការដោះស្រាយវិវាទការងារនៅកម្ពុជា និង (៣)គំរោង ស្តីពីការបង្កើតក្រុមប្រឹក្សាអជ្ញាកណ្តាល ។ ឆ្លងតាមការអនុវត្តគំរោងទាំងនេះ ក្រសួងពិនិត្យឃើញថា សហគមអន្តរជាតិទទួលស្គាល់ថា លក្ខខណ្ឌការងារនៅកម្ពុជាល្អប្រសើរ មិនមានការប្រើប្រាស់ពលកម្មកុមារ និងមិនមានពលកម្មដោយចាប់បង្ខំស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ហើយដែលតាមរយៈនោះ កូតារង្វាន់នៃការនាំចេញផលិតផលត្រូវបានភាគីអាមេរិកបង្កើនឡើង ។ វិវាទដែលកើតឡើងជារៀងរាល់ឆ្នាំបានថយចុះ ទោះបីជាចំនួនគ្រឹះស្ថានកើនឡើងក៏ដោយ ។ ក្រសួងបានសង្កេតឃើញថា និន្នាការនៃការជំរុញករណីវិវាទឱ្យឡើងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងតុលាការបានថយចុះ គឺអត្រានៃករណីដែលត្រូវបានដោះស្រាយរួចរាល់ ដោយការសម្រុះសម្រួល និងផ្សះផ្សាបានកើនឡើង ។ វិធានការនេះ ក្រសួងនៅតែបន្តអនុវត្តជាលំដាប់លំដោយ បើពិនិត្យឃើញមានការខ្វះខាត និងមានការកែលំអបន្ថែមតទៅទៀត ។ ក្នុងពេលបច្ចុប្បន្ននេះករណីដែលក្រុមប្រឹក្សាការងារអណត្តិទី ៣ ពេលកើតឡើងជាផ្លូវការហើយ អាចជួយសម្រួលភាគីទាំងសងខាងនិយោជក និងកម្មករនិយោជិតឱ្យមានការយល់ដឹងគ្នាទៅវិញទៅមកកាន់តែប្រសើរឡើងថែមទៀត ។

**សំណួរទី២២ : របាយការណ៍បានបង្ហាញអោយឃើញថា ប្រទេសកម្ពុជាមានអត្រាកំលាំងពលកម្មស្ត្រីចូលរួមខ្ពស់បំផុតក្នុងតំបន់ ប៉ុន្តែស្ត្រីភាគច្រើនធ្វើការនៅក្នុងវិស័យក្រៅផ្លូវការ ធ្វើការងារដែលមានប្រាក់កម្រៃទាបការងារដែលគ្មានជំនាញ ហើយរបាយការណ៍ក៏បង្ហាញអោយឃើញថា ស្ត្រីជាជនងាយរងគ្រោះដោយសារការកេងប្រវ័ញ្ចជាច្រើនរូបភាពនៅក្នុងកន្លែងធ្វើការ (ទំព័រទី៥៨) ។ សូមផ្តល់ព័ត៌មានអំពីវិស័យក្រៅផ្លូវការ-ផ្នែកនិយាយអំពីវិស័យ និងផ្នែកឈរនិយាយអំពីលំដាប់លេខរៀង និងត្រូវបែងចែកតាមភេទ?**

**ចម្លើយ ៖**

### ១. ស្ត្រីក្នុងកំលាំងពលកម្ម

តាមរបាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០០៣-០៤ (ទិន្នន័យ១២ខែ) ស្ត្រីកម្ពុជាក្នុងអាយុពលកម្មសរុបពី ១០ឆ្នាំឡើងទៅមាន ៥ ២៨២ ០៥៣នាក់ ដែលក្នុងនោះ ៣ ៧០២ ៣០៧ នាក់ ឬស្មើនឹង ៧០,៧ ភាគរយ ជាប្រជាជនសកម្មក្នុងវិស័យសេដ្ឋកិច្ច ដែលទាបជាងអត្រាបុរសសកម្មក្នុងវិស័យសេដ្ឋកិច្ច ៧៨,៩ ភាគរយ ក្នុងចំណោមបុរសអាយុពលកម្មសរុប។ ដោយឡែក នៅជនបទដែលធម្មតាកំលាំងសកម្មតែងខ្ពស់ជាងនៅទីប្រជុំជន និងទីក្រុងភ្នំពេញ មានអត្រាចូលរួមស្ត្រី៧៣.០ ភាគរយនិងបុរស ៨១.៤ ភាគរយ អត្រាមានការងារធ្វើ ស្ត្រី ៩៩.៥ ភាគរយ និងបុរស ៩៩.៤ ភាគរយ។ អត្រាចូលរួមកំលាំងពលកម្មរបស់ស្ត្រីកម្ពុជា ឆ្នាំ២០០៣/២០០៤ មាន ៤៩.៤ ភាគរយនៃកំលាំងពលកម្មសរុប។

តាមរបាយការណ៍អភិវឌ្ឍន៏មនុស្សនៅកម្ពុជាឆ្នាំ ១៩៩៨ ស្ត្រីកម្ពុជាមានចំនួន ៥៣ ភាគរយនៃកំលាំងពលកម្មមនុស្សពេញវ័យសរុប (អាយុពី១៥ ឆ្នាំឡើង) នៅក្នុងប្រទេសកម្ពុជា (យោងទៅលើអង្កេតសេដ្ឋកិច្ច - សង្គមកិច្ច (CSES) ឆ្នាំ១៩៩៧) គឺច្រើនជាងនៅប្រទេសក្នុងភូមិភាគអាស៊ីអគ្នេយ៍ដទៃៗទៀត ដូចជាស្ត្រីវៀតណាមមានតែ ៤៩ ភាគរយក្នុងកំលាំងពលកម្ម ឥណ្ឌូនេស៊ី ៤០ ភាគរយ ម៉ាឡេស៊ី ៣៧ ភាគរយ ។ល។ (ប្រភព : UNDP(១៩៩៨) និង (CSES) ឆ្នាំ១៩៩៧)។

### ២. ការបែងចែកមុខរបររវាងបុរស និងស្ត្រី

កម្ពុជាជាប្រទេសកសិកម្មមួយ។ ទោះជា មានចំណាកស្រុក (Migration) ខ្លះនៃការងារយុវជនមកកាន់កម្មន្តសាលកាត់ដេរ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏នៅតែរក្សាកំលាំងការងារក្នុងកសិកម្ម រុក្ខា និងប្រមាញ់ប្រមាណ ៥៥,៥ ភាគរយ និងក្នុងនេសាទ ៤,៨ ភាគរយ។ ដូច្នេះ ក្នុងវិស័យនេះមានការធ្លាក់ចុះច្រើនគឺ ១៩,០ ភាគរយ ពី ៧៤,៦ ភាគរយនៅឆ្នាំ១៩៩៩ មក ៥៥,៥ ភាគរយនៅឆ្នាំ២០០៤។ មុខរបរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ការងារ៦១,៧ ភាគរយ (ស្ត្រី៦០,៣% បុរស៦៣,០%) ធ្លាក់ចុះប្រហែលជាង១២,០ ភាគរយ ពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៩។ រីឯផលិតផលសរុបក្នុងស្រុក (ផ.ស.ស) ក្នុងវិស័យនេះ តាមថ្លៃថេរក្នុងគណនេយ្យជាតិ បានធ្លាក់ចុះជាង១២,៣ ភាគរយពី ៤២,៨ ភាគរយនៅឆ្នាំ ១៩៩៧ មក ៣០,៥ ភាគរយនៅឆ្នាំ២០០៤។

សម្រាប់របរជំនួញលក់ដុំ និងលក់រាយ ចំណែកក្នុងការងារសរុបមាន ១៣,៩ ភាគរយ (ស្ត្រី ១៨,៨ % បុរស ៩,០ %) ដូច្នេះប្រហែលស្មើនឹង២ ដងលើសពីអង្កេតមុនៗ។ ពិសេសសម្រាប់ភ្នំពេញ ចំណែកនៃវិស័យនេះបានរីក និងទទួលបានស្មើនឹង ៣៥,៧ ភាគរយ (ស្ត្រី ៤៨,០% បុរស ២៤,៤%)។

| ការបែងចែកជាភាគរយនៃអ្នកធ្វើការ(អាយុ១០ឆ្នាំឡើង)តាមមុខរបរសំខាន់ៗ និងភេទ | | |
|---|---|---|
| | **១៩៩៧** | **២០០៤** |

| មុខរបរសំខាន់ៗ | ស្ត្រី | ប្រុស | ស្ត្រី | ប្រុស |
|---|---|---|---|---|
| ១. អ្នកតាក់តែងច្បាប់ មន្ត្រីជាន់ខ្ពស់ អ្នកគ្រប់គ្រង | ០,២១ | ២,៩០ | ០,៣ | ១,៥ |
| ២. អ្នកអាជីព | ១,២៣ | ២,៨៥ | ១,៩ | ៣,៨ |
| ៣. អ្នកបច្ចេកទេស និងអាជីពបន្ទាប់បន្សំ | ១,០២ | ៣,៧៤ | ០,៣ | ០,៦ |
| ៤. ស្មៀន ឬលេខាធិការ | គ្មានតួលេខ | គ្មានតួលេខ | ០,២ | ០,១ |
| ៥. អ្នកលក់ទំនិញនៅហាង និងផ្សារ | ១០,១៥ | ៤,៦១ | ១៦,៧ | ៨,០ |
| ៦. កសិករ និងអ្នកនេសាទ | ៨០,៣៤ | ៧៣,៤៣ | ៦០,៣ | ៦៣,០ |
| ៧. បុគ្គលិកសិប្បកម្ម និងជំនួញពាក់ព័ន្ធ | ៣,២០ | ៤,៤៣ | ៦,២ | ៥,០ |
| ៨. ការិរោងចក្រ និងម៉ាស៊ីន ... | ០,៣២ | ២,៧៩ | ៥,៥ | ៥,៧ |
| ៩. មុខរបរបឋម | ៣,៤២ | ៥,០៨ | ៦,៣ | ៩,៣ |
| ១០. កំលាំងប្រដាប់អាវុធ | គ្មានតួលេខ | គ្មានតួលេខ | ០,១ | ១,៣ |
| ១១. ក្រុមមុខរបរផ្សេងៗ (ក្រៅផ្លូវការ) | ០,១២ | ០,១៦ | ២,២ | ១,៥ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

ប្រភព : អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (CSES) ឆ្នាំ១៩៩៧ និង ឆ្នាំ២០០៤

នៅកម្ពុជាមនុស្សពេញវ័យដែលសកម្មក្នុងផ្នែកសេដ្ឋកិច្ចភាគច្រើនបំផុតគឺ ៦០,៣ ភាគរយនៃស្ត្រី និង ៦៣,០ ភាគរយនៃបុរស គឺជាកសិករ និងអ្នកនេសាទ (ពិនិត្យតារាងខាងលើ)។ ស្ត្រីធ្វើការខាងសេវាកម្មច្រើនជាងបុរស ជាម្ចាស់ហាង ឬអ្នកលក់នៅតាមផ្សារ (ជាង ១៦,៧ ភាគរយនៃស្ត្រីដែលធ្វើការជាបុគ្គលិកសេវាកម្ម ប៉ុន្តែបុរសដែលធ្វើការក្នុងផ្នែកនេះមានតែ ៨,០ ភាគរយប៉ុណ្ណោះ )។

ទិន្នន័យ ស្តីពីការចូលរួមក្នុងកំលាំងពលកម្មមិនបានបង្ហាញពេញលេញពីបន្ទុកការងាររបស់ស្ត្រីឡើយ។ ដូចនៅក្នុងប្រទេសដទៃទៀតនៅអាស៊ី ស្ត្រីនៅកម្ពុជាដែលធ្វើការខាងក្រៅផ្ទះក៏ត្រូវធ្វើកិច្ចការក្នុងផ្ទះភាគច្រើនដែរ ដោយមានការជួយពីកូនស្រី ប៉ុន្តែការងារមិនត្រូវបានកត់ត្រាទេ។

### ៣. ការបែងចែកប្រាក់បៀវត្សរ៍តាមភេទ

ដោយសារអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ បានទទួលព័តិមាន ស្តីពីមុខរបរ ប្រាក់ចំណូលប្រចាំខែ ការអប់រំ និងអាយុរបស់បុគ្គលម្នាក់ៗដែលធ្វើការ គេអាចពិនិត្យលើប្រាក់ខែរបស់បុរស និងស្ត្រីក្នុងមុខរបរដូចគ្នា និងមានការអប់រំ និងអាយុស្មើគ្នា ។

ទិន្នន័យនោះបង្ហាញថា នៅកម្ពុជាសំរាប់មុខរបរនីមួយៗនៅក្នុងចំណោមមុខរបរទាំង៦ដែលអាចមានទិន្នន័យ ស្តីពីប្រាក់បៀវត្សរ៍គ្រប់គ្រាន់នោះ ប្រាក់ចំណូលរបស់បុរស គឺខ្ពស់ជាងប្រាក់ចំណូលរបស់ស្ត្រីគួរឱ្យកត់

សម្គាល់។ភាពខុសគ្នានេះប្រែប្រួលពីទាប ១៦ ភាគរយសំរាប់ (អ្នកធ្វើសិប្បកម្ម និងជំនួញពាក់ពន្ធ័នានា) ទៅខ្ពស់ ៨៤ ភាគរយសម្រាប់ ( ការីរោងចក្រ និងអ្នកតំលើងម៉ាស៊ីន )។ ជាមធ្យមបុរសរកប្រាក់ចំណូលប្រហែល ៥០ ភាគរយ ច្រើនជាងស្ត្រីនៅក្នុងមុខរបរដូចគ្នា (យោងតាមរបាយការណ៏អភិវឌ្ឍន៏មនុស្សឆ្នាំ១៩៩៨ របស់ក្រសួងផែនការ)។ ទិន្នន័យរបាយការណ៏តំបូងនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០៣/០៤ពុំទាន់មានសម្រាប់ប្រើប្រាស់បាន តែនិន្នាការលំអៀង ឬគំលាតនៃប្រាក់ចំណូលរវាងបុរស និងស្ត្រីនឹងមានការថយចុះ។

**សំណួរទី២៣ : សូមផ្តល់ព័ត៏មានស្តីពីកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែអនុវត្ត ដើម្បីអោយស្ត្រីទទួលបាននូវការបណ្តុះបណ្តាល លក្ខខណ្ឌការងារល្អប្រសើរ និងការការពារផ្នែកសង្គមកិច្ច ?**

**ចម្លើយ :**

សូមរាយការណ៏ជូនថា អំពីកម្មករ និយោជិត នៅក្នុងសហគ្រាសកាត់ដេរនៅកម្ពុជាជាទូទៅ គឺស្ត្រី ព្រោះថាមានស្ត្រីរហូតដល់ ៩០ភាគរយ នៃចំនួនសរុប។ ដើម្បីធានាឱ្យស្ត្រីទទួលនូវការបណ្តុះបណ្តាលលក្ខខណ្ឌការងារល្អប្រសើរ និងការការពារផ្នែកសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានខិតខំប្រឹងប្រែងធ្វើការដូចខាងក្រោម :

<u>ការធ្វើឱ្យស្ត្រីទទួលបានការបណ្តុះបណ្តាល</u> :

- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចេញប្រកាស លេខ០០៤ សកបយ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាងរយៈពេលខ្លី (២ខែ) មុននឹងចូលធ្វើការ និងការកំណត់អត្រាឱ្យគ្រឹះស្ថាននីមួយៗទទួលយកកូនជាងធ្វើការហ្វឹកហ្វឺន (អត្រាពី ៨ ទៅ ១០ភាគរយ នៃចំនួនកម្មករសរុប)។

យោងតាមជំពូក ៣នៃច្បាប់ ស្តីពីការងារ (មាត្រា ៥១ ដល់ ៦៤)។

- សេចក្តីណែនាំ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ០០៣ សកបយ ចុះថ្ងៃទី ៣ ខែមិនា ឆ្នាំ ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្ត ប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលជាក្រសួងបន្តវេនវិស័យការងារពីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចាត់មន្ត្រីជំនាញទៅពិនិត្យការអនុវត្តប្រកាសនេះ និងចេញវិញ្ញាបនប័ត្រ ទទួលស្គាល់ការហ្វឹកហ្វឺន។ ចំពោះគ្រឹះស្ថានណាដែលមិនព្រមអនុវត្ត ឬមានការយឺតយ៉ាវក្នុងការអនុវត្តក្រសួងតម្រូវអោយអនុវត្តជាកំហិត។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងនៅរាជធានីភ្នំពេញ ទាំងខេត្ត ក្រុងនានា ដើម្បីយុវជន ជាពិសេសនារី និងជនក្រីក្រ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខិតខំកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងចេញប្រកាសសេចក្តីណែនាំខាងលើនេះ សំដៅធ្វើឱ្យយុវជនដែលមិនទាន់មានជំនាញ ពិសេសយុវនារីទទួលបានការបណ្តុះ-បណ្តាលមួយធ្វើឱ្យមានសមត្ថភាពធ្វើការ ដែលជាកត្តានាំទៅដល់ការទទួលបានការងារសមរម្យធ្វើ ។

<u>ការធ្វើឱ្យស្ត្រីទទួលបានលក្ខខណ្ឌការងារល្អប្រសើរៈ</u>

យោងចម្លើយទៅនឹងសំនួរទី ២១ ខាងលើ ។

<u>ការធ្វើឱ្យស្ត្រីទទួលបានការការពារផ្នែកសង្គមកិច្ចៈ</u>

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបន្ទុកវិស័យការងារ សហការជាមួយក្រសួងសុខាភិបាល នៃក្រសួងកិច្ចការនារី ក្នុងការណែនាំអប់រំ កម្មការិនីទៅតាមសហគ្រាសកាត់ដេរនានាឱ្យបានយល់ដឹងអំពីការថែទាំសុខភាព ជាពិសេសការយល់ដឹងអំពីជំងឺអេដស៍ ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់មន្ត្រីពេទ្យការងារទៅតាមសហគ្រាស ដើម្បីពិនិត្យមើលការកំណត់ឱ្យសហគ្រាសនីមួយៗ រៀបចំឱ្យមានទឹកល្អប្រើប្រាស់ បង្គន់អនាម័យ ជាពិសេសធ្វើការណែនាំពន្យល់អំពីរោគស្ត្រី ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាលបានចេញប្រកាសរួមលេខ ៣៣០ សកបយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២000 ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ដែលកំណត់ឱ្យគ្រឹះស្ថាននីមួយៗ រៀបចំឱ្យមានគិលានដ្ឋានអចិន្ត្រៃយ៍ ឬបន្ទប់រំរបួស ឬប្រអប់សង្គ្រោះ ទៅតាមទំហំតូច ឬធំ ដែលមានកម្មករនិយោជិតតិច ឬច្រើន ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកំពុងសហការជាមួយ អង្គការអន្តរជាតិខាងការងារធ្វើការសិក្សា និងរៀបចំជាគំរោងកម្មវិធីរយៈពេល៥ឆ្នាំ (២00៦-២0១0) ស្តីពីអនាម័យ និងសុខភាពនៅកន្លែងធ្វើការ ដើម្បីបានជាទិសដៅសម្រាប់ការងារបង្ការ និងការពារសុខភាព និងសុវត្ថិភាពការងាររបស់កម្មករ និយោជិត ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់មន្ត្រីជំនាញអោយទៅពិនិត្យនៅតាមរោងចក្រសហគ្រាសនានា អំពីការអនុវត្តការបង្ការ និងការពារសុខភាព និងសុវត្ថិភាពការងាររបស់កម្មករនិយោជិត ដោយបានពន្យល់កម្មករ និយោជិតឱ្យយល់ដឹងអំពីការងារនេះ និងត្រួតពិនិត្យមើលសម្ភារៈ និងឧបករណ៍ដែលកម្មករនិយោជិតប្រើប្រាស់ ធានាមានសុវត្ថិភាព ក៏ដូចជាការកំណត់ឱ្យប្រើប្រាស់សម្ភារៈការពារបុគ្គលជាដើម ។

**សំណួរទី២៤ : សូមផ្តល់ព័ត៌មាន ស្តីពីសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រីជនបទ និងកម្រិតនៃប្រាក់ចំណូលរបស់ពួកគេ ប្រៀបធៀបជាមួយនឹងប្រាក់ចំណូលរបស់បុរស ។**

**ចម្លើយ ៖**

ដោយសារការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៧ បានទទួលពត៌មាន ស្តីពីមុខរបរ ប្រាក់ចំណូលប្រចាំខែ ការអប់រំ និងអាយុរបស់បុគ្គលម្នាក់ៗដែលធ្វើការ គេអាចពិនិត្យលើប្រាក់ខែរបស់បុរស និងស្ត្រីក្នុងមុខរបរដូចគ្នា និងមានការអប់រំ និងអាយុស្មើគ្នា។

ទិន្នន័យនោះបង្ហាញថា នៅកម្ពុជា សម្រាប់មុខរបរនីមួយៗនៅក្នុងចំណោមមុខរបរទាំង៦ ដែលអាចមានទិន្នន័យ ស្តីពីប្រាក់បៀវត្សរ៍គ្រប់គ្រាន់នោះ ប្រាក់ចំណូលរបស់បុរស គឺខ្ពស់ជាងប្រាក់ចំណូលរបស់ស្ត្រីគួរឱ្យកត់សម្គាល់។ ភាពខុសគ្នានេះប្រែប្រួលពីទាប ១៦ ភាគរយសំរាប់ (អ្នកធ្វើសិប្បកម្ម និងជំនួញពាក់ពន្ធ័នានា) ទៅខ្ពស់៨៤ ភាគរយសម្រាប់ (ការីរោងចក្រ និងអ្នកតំលើងម៉ាស៊ីន )។ ជាមធ្យមបុរសរកប្រាក់ចំណូលប្រហែល ៥០ ភាគរយ ច្រើនជាងស្ត្រីនៅក្នុងមុខរបរដូចគ្នា(យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ១៩៩៨ របស់ក្រសួងផែនការ)។ ទិន្នន័យរបាយការណ៍ដំបូងនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០០៣/០៤ពុំទាន់មានសម្រាប់ប្រើប្រាស់បាន តែនិន្នាការលំអៀង ឬគំលាតនៃប្រាក់ចំណូលរវាងបុរស និងស្ត្រីនឹងមានការថយចុះ។ ដោយឡែក ចំពោះស្ត្រីនៅក្នុងក្របខណ្ឌរាជការ និងកងប្រដាប់អាវុធ មានប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់ស្មើគ្នានឹងបុរស ក្នុងករណីមុខដំណែង និងឋានៈស្មើគ្នា។

***សំណួរទី២៥ ៖ មាត្រា១០៦ នៃច្បាប់ការងារឆ្នាំ១៩៩៧ ចែងអំពីការផ្តល់ “ប្រាក់បៀវត្សរ៍“ ទៅតាម “លក្ខខណ្ឌការងារ ជំនាញ និងលទ្ធផលការងារស្មើគ្នា”។ សូមផ្តល់ព័ត៌មានបញ្ជាក់ថាតើមានការអនុវត្តចំណុចនេះទេ? ថាតើចំណុចនេះត្រូវបានយកទៅអនុវត្ត ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីដែរឬទេ? សូមបញ្ជាក់ផងដែរថា តើច្បាប់ការងារមានឃាត់ឃាំងចំពោះការរើសអើងផ្សេងៗទៀតនៅក្នុងការបែងចែកផលប្រយោជន៍ដែរឬទេ?***

**ចម្លើយ ៖**

ចំណុចនេះត្រូវបានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យកចិត្តទុកដាក់យ៉ាងខ្លាំង ដោយបាននិងកំពុងចាត់វិធានការដាក់ឱ្យអនុវត្ត និងតាមការពិនិត្យមើលការអនុវត្តជាប្រចាំ តាមរយៈការងារមួយចំនួនដូចខាងក្រោមៈ

- អនុវត្តមាត្រា ៩៦ ដល់មាត្រា ១០១ ផ្នែកទី៥ ជំពូកទី៥ នៃច្បាប់ស្តីពីការងារ កម្មករនយោជិត និងនយោជកអាចព្រមព្រៀងគ្នាធ្វើអនុសញ្ញារួមដែលមានផលប្រយោជន៍លើសពីការកំណត់ក្នុងច្បាប់នេះ។ អនុលោមតាមបទបញ្ញត្តិនៃច្បាប់នេះកន្លងមក កម្មករនិយោជិត និងនយោជកវិស័យកាត់ដេរ និងវិស័យទេសចរណ៍នៅកម្ពុជាបានព្រមព្រៀងគ្នាធ្វើអនុសញ្ញារួមជាបន្តបន្ទាប់ ដើម្បីកំណត់អំពីសិទ្ធិ និងផលប្រយោជន៍ដែល

កម្មករនិយោជិតនឹងទទួលបានលើសពីច្បាប់ ដូចជាការកំណត់ប្រាក់ឈ្នួលអប្បបរមា ការបែងចែកប្រាក់ធនាអនុ-គ្រោះ ការឈប់សម្រាកផ្សេងៗជាដើម ។

- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាបានចេញសេចក្តីជូនដំណឹងចំនួន ២ ដល់កម្មករនិយោជិតនៃសហគ្រាសកាត់ដេរ :(១)សេចក្តីជូនដំណឹង លេខ ០៦ សកអ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៧ ស្តីពីការផ្តល់ប្រាក់ឈ្នួលអប្បបរមាជូនកូនជាងក្នុងពេលហ្វឹកហ្វឺនកូនជាង ។ (២) សេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការផ្តល់ប្រាក់ឈ្នួលអប្បបរមាចំពោះកម្មករនិយោជិតក្នុងរយៈពេលធ្វើការសាកល្បង និងពេញសិទ្ធិ ប្រាក់អតីតភាពការងារ និងប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់ ។

- ដើម្បីអនុវត្តទូទៅនៅគ្រប់សហគ្រាស នូវមាត្រា ១២ ផ្នែកទី ២ ជំពូកទី១ នៃច្បាប់ស្តីពីការងារ ដែលចែងអំពីការមិនរើសអើង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាបានចេញប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ដើម្បីធានាអោយបានថា កូនជាងទាំងស្ត្រី និងបុរស ត្រូវតែទទួលបានប្រាក់ឈ្នួលដូចគ្នា ក្នុងពេលហ្វឹកហ្វឺនដូចគ្នា ។

- យោងតាមច្បាប់ស្តីពីការងារ ត្រង់មាត្រា ១០៤ ប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានធានាគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពី ការងារនៅព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងអនុវត្ត ។

អាស្រ័យដោយមានការព្រមព្រៀងគ្នា រវាងកម្មករនិយោជិត និងនិយោជក ដោយមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ ដោយមិនមានចំណុចណាមួយដែលរើសអើងអំពីអ្វីមួយឡើយ តែត្រូវបានអនុវត្តដោយស្របទៅតាមលក្ខខណ្ឌការងារជំនាញ និងលទ្ធផលការងារស្មើគ្នា ស្របតាមច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ ។

***សំណួរទី២៦ : ប្រទេសកម្ពុជានាពេលថ្មីៗនេះ បានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក និងមានការបញ្ឈប់កិច្ចព្រមព្រៀងសារពើពន្ធ ដូច្នេះសូមផ្តល់ព័ត៌មានថាតើមានការដំណើរការវាយតម្លៃអំពីផលប៉ះពាល់ទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ស្ត្រីដែរឬទេ ក្នុងគោលបំណងដើម្បីរៀបចំគោលនយោបាយសេដ្ឋកិច្ចមាក្រូឡើងវិញអោយឆ្លើយតបទៅនឹងលទ្ធផលនៃការវាយតម្លៃនេះ?***

**ចម្លើយ :**

ក្រោយ និងមុនពេលដែលប្រទេសកម្ពុជា បានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយពេលដែលកូតាសំលៀកបំពាក់ត្រូវបានបញ្ចប់ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០០៥ តាមកិច្ចព្រមព្រៀងលើវាយណភ័ណ្ឌ និងសំលៀកបំពាក់របស់អង្គការពាណិជ្ជកម្មពិភពលោក ស្ថានភាពលើវិស័យកាត់ដេរនៅប្រទេសកម្ពុជា នៅតែបន្តការនាំចេញជាធម្មតា ហើយគ្មានផលប៉ះពាល់អ្វីដល់ឧស្សាហកម្មកាត់ដេរ ពិសេសគ្មានមានការ

ប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ស្ត្រីខ្មែរទេ។ យោងតាមស្ថិតិនាំសំលៀកបំពាក់ទៅអាមេរិក ត្រឹមរយៈពេល ១០ ខែ នៅឆ្នាំ ២០០៥ នេះ ការនាំចេញបានកើនឡើង ១៦% បើប្រៀបជាមួយរយៈពេលដូចគ្នានៃឆ្នាំ ២០០៤។ ទន្ទឹមនោះ ចំនួនរោងចក្រកាត់ដេរបានកើនឡើងពីចំនួន ២០០ ទៅដល់ ២៤៨ រោងចក្រ នៅឆ្នាំ ២០០៥ នេះដែរ។

ដូច្នេះ នៅពេលដែលប្រទេសកម្ពុជាបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ផលិតផលនាំចេញ ជាពិសេសផលិតផលក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌកម្ពុជាអាចប្រកួតប្រជែងនៅលើទីផ្សារដដែល។ អាស្រ័យដោយលក្ខខណ្ឌការងារកាន់តែប្រសើរ ដែលធ្វើឱ្យអតិថិជនមានទំនុកចិត្តលើកេរ្តិ៍ឈ្មោះរបស់កម្ពុជា គឺជាកត្តាធ្វើអោយផលិតផលអាចប្រកួតប្រជែងនៅលើទីផ្សារ និងរក្សាបានទីផ្សារការងារមួយដ៏សមរម្យនៃវិស័យនេះ។ ប្រការនេះមានសារៈសំខាន់ណាស់ ចំពោះការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ស្ត្រី ទើបរាជរដ្ឋាភិបាលកម្ពុជាមានវិធានការនៅចម្លើយទី ២១ និងទី ២៥ ខាងលើជាបន្តជាប់ជាប្រចាំ ដែលជាហេតុធ្វើអោយលក្ខខណ្ឌការងារមានលក្ខណៈល្អប្រសើរនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងវាយនភ័ណ្ឌ។

## មាត្រា ១២

**សំណួរទី២៧ : ទំព័រទី៦២-៦៣ រៀបរាប់អំពីកម្មវិធីសុខភាពមួយចំនួនស្តីពីសុខភាពបន្តពូជ អាហាររូបត្ថម្ភ ជំងឺហ៊ីវ/អេដស៍ និងសុខភាពផ្លូវចិត្តសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែរបាយការណ៍ក៏បាននិយាយថា ការយល់ដឹងអំពីបញ្ហាទាំងនេះ និងបញ្ហាសុខភាពផ្សេងៗទៀតនៅមានកំរិតទាបបំផុត (ទំព័រទី ៥៣ កថាខណ្ឌ ២៧៥) សេវាថែទាំសុខភាពសម្រាប់ស្ត្រីនៅមានកម្រិត (ទំព័រទី ៦៧ កថាខណ្ឌ ៣៥០)មានតែ ១០ភាគរយប៉ុណ្ណោះដែលសំរាលកូននៅក្នុងមណ្ឌលសុខភាព (ទំព័រទី ៦៤ កថា ខណ្ឌ ៣៣១) ហើយអត្រាមរណភាពមាតាមានកម្រិតខ្ពស់។ សូមផ្តល់ព័ត៌មានជាក់លាក់អំពីវិធានការដែលមាន ដើម្បីបង្កើនការយល់-ដឹងរបស់ស្ត្រី និងការបង្កើនឱកាសដើម្បីទទួលបានសេវាថែទាំសុខភាពទូទៅ និងសម្ភព?**

**ចម្លើយ :**

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ស្ត្រី និង បង្កើនឱកាសដើម្បីទទួលបានសេវាថែទាំសុខភាពទូទៅ និងសម្ភព រដ្ឋាភិបាលបានដាក់ចុះនូវវិធានការជាច្រើនដែលអនុវត្តដោយក្រសួងសុខាភិបាលតាមរយៈសេវាសុខាភិបាលសាធារណៈ សហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយនានា :

**ក- វិធានការដែលអនុវត្តតាមរយៈសេវាសុខាភិបាលសាធារណៈ**

១- ផ្តល់ការអប់រំសុខភាពអំពីសុខភាពបន្តពូជ អាហារូបត្ថម្ភ ការឆ្លងមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាពផ្លូវចិត្តសម្រាប់គ្រប់ប្រជាពលរដ្ឋនៅនឹងមណ្ឌលសុខភាពក្នុងមួយសប្តាហ៍ម្តងតាមពេលវេលា និងផែនការកំណត់។

២- ផ្តល់ព័ត៌មានសំខាន់ៗអំពីសុខភាពបន្តពូជ អាហារូបត្ថម្ភ ការឆ្លងមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាពផ្លូវចិត្តដល់ស្ត្រីមានផ្ទៃពោះ និងប្តី តាមរយៈថ្នាក់អប់រំម្តាយនៅពេលដែលស្ត្រីមានផ្ទៃពោះមកពិនិត្យផ្ទៃពោះ (ដោយមានប្តីជូនមក) នៅនឹងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។ យើងលើកទឹកចិត្តឱ្យមានការចូលរួមរបស់ប្តី និងបុរស ក្នុងការពិភាក្សានៅក្នុងថ្នាក់អប់រំម្តាយ និងក្នុងពេលផ្តល់សេវាសុខភាពដទៃទៀត។

៣- ផ្តល់ការពិគ្រោះយោបល់ (មួយទល់មួយ) ដល់ស្ត្រីមានផ្ទៃពោះនៅក្នុងពេលកំពុងពិនិត្យផ្ទៃពោះ ក្នុងពេលសម្រាលកូន និងរយៈពេលក្រោយសម្រាលភ្លាម អំពីសញ្ញាគ្រោះថ្នាក់ ការបំបៅកូនដោយទឹកដោះម្តាយ អាហារបន្ថែមសម្រាប់ទារក អាហាររូបត្ថម្ភ អនាម័យ ការទប់ស្កាត់ការឆ្លងរោគពីម្តាយទៅកូន ពន្យារកំណើត និងការថែទាំទារក។

៤- បង្កើតសេវាពិសេសសម្រាប់ស្ត្រីដែលមានបញ្ហាផ្លូវចិត្តជាទូទៅ និងក្រោយពេលសម្រាលកូនរួច។

៥- ឆ្មប និងបុគ្គលិកមណ្ឌលសុខភាព ចុះធ្វើសកម្មភាពផ្តល់សេវាតាមមូលដ្ឋានសហគមន៍ (ភូមិ) ដែលរួមមានផ្តល់ថ្នាំបង្ការជម្ងឺ៧មុខ (របេង ស្វិតដៃជើង ខាន់ស្លាក់ ក្អកមាន់ តេតាណូស កញ្ជ្រឹល រលាកថ្លើមប្រភេទបេ) ការចែកវីតាមីនអា ការចែកគ្រាប់ថ្នាំជាតិ ដែក/អាស៊ីដហ្វូលីក ការពិនិត្យផ្ទៃពោះ ការសម្រាលកូននៅតាមផ្ទះ ការថែទាំក្រោយសម្រាល និងអប់រំសុខភាព។

៦- បុគ្គលិកសុខាភិបាល ផ្តល់ការអប់រំជាទូទៅដល់គ្រប់ប្រជាពលរដ្ឋ (ស្ត្រី បុរស គ្រួសារ មេភូមិ អ្នកស្ម័គ្រចិត្តក្នុងភូមិ គ្រូបង្រៀន សិស្សសាលា តាអាចារ្យ ព្រះសង្ឃ ដូនជី ក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម) ឱ្យយល់ដឹងពីជម្ងឺឆ្លងនានា (របេង គ្រុនចាញ់ គ្រុនសន្និ គ្រុនឈាម ជម្ងឺរាក គ្រុនពោះវៀន ជម្ងឺដង្កូវពោះវៀន រលាកថ្លើមប្រភេទបេ ជម្ងឺកាម រោគ មេរោគអេដស៍ជាដើម ) យល់ដឹងអំពីប្រភពនៃជម្ងឺឆ្លងនានា យល់ដឹងពីផ្លូវចម្លង និងភ្នាក់ងារចម្លងមេរោគ ស្គាល់ពីសញ្ញាគ្រោះថ្នាក់នានាដែលបណ្តាលមកពីជម្ងឺឆ្លង ការធ្វើអនាម័យ ការបង្ការទប់ស្កាត់ការចម្លងមេរោគ និងស្គាល់ពីទីកន្លែងដែលមានសេវាសុខភាពពិនិត្យ និងព្យាបាល។

៧- ផ្តល់ការអប់រំជាទូទៅដល់គ្រប់ប្រជាពលរដ្ឋ (ស្ត្រី បុរស គ្រួសារ មេភូមិ អ្នកស្ម័គ្រចិត្តក្នុងភូមិ តាអាចារ្យ ព្រះសង្ឃ ដូនជី ក្រុមប្រឹក្សាឃុំ) ឱ្យយល់ដឹងអំពីជម្ងឺដែលមិនឆ្លង ដូចជាជម្ងឺមហារីក

៨- ពង្រីកសេវាសុខភាពឱ្យបានគ្រប់ទីកន្លែងតាមយុទ្ធសាស្ត្រ ទិសដៅ និងតាមផែនការកំណត់ ដើម្បីបង្កើនការទទួលបានសេវាសុខភាព ជាពិសេសសេវាសម្រាប់ស្ត្រី ទារក កុមារ និងសេវាសម្ភព ។

៩- ផ្តល់សេវាសុខភាពដោយលើកលែងការបង់ថ្លៃឬផ្តល់មូលនិធិសមធមិចំពោះអ្នកក្រីក្រ ។

១០-បង្កើន និងពង្រឹងកិច្ចសហការជាមួយបណ្តាដៃគូអភិវឌ្ឍសុខាភិបាល អង្គការក្រៅរដ្ឋាភិបាលទាំងអស់ក្នុងការបង្កើនការយល់ដឹងផ្នែកសុខភាព ក៏ដូចជាការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ ជាពិសេសជូនស្ត្រី ទារក និងកុមារ ។

១១- បង្កើន និងពង្រឹងកិច្ចសហការជាមួយបណ្តាដៃគូអភិវឌ្ឍសុខាភិបាល អង្គការក្រៅរដ្ឋាភិបាលទាំងអស់ក្នុងការបង្កើនការយល់ដឹងក្នុងករណីពិសេស ជាអាទិ៍ គ្រោះមហន្តរាយដោយទឹកជំនន់ គ្រោះរាំងស្ងួត ការផ្ទុះឡើងនូវជម្ងឺឆ្លងថ្មីៗដូចជា ជម្ងឺគ្រុនបក្សីនិង ជម្ងឺសារស៍ ជាដើម ។ ពង្រឹងវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺឆ្លងនានា ពង្រឹងប្រព័ន្ធបញ្ជូនជម្ងឺ ប្រព័ន្ធសង្គ្រោះបន្ទាន់ និងការព្យាបាលសមស្រប ។

**ខ- តាមរយៈការចូលរួមរបស់សហគមន៍ ដើម្បីបង្កើនការយល់ដឹង និងបង្កើនឱកាសដើម្បីទទួលបានសេវាថែទាំសុខភាពទូទៅ និងសម្ភព និងការបញ្ជូនអ្នកជម្ងឺ :**

១- បណ្តុះបណ្តាលឆ្មបបូរាណអំពីសញ្ញាគ្រោះថ្នាក់នានា ដែលអាចកើតមានក្នុងពេលមានផ្ទៃពោះ ពេលសម្រាលកូន និងក្រោយពេលសម្រាលកូន គ្រោះថ្នាក់ដែលបណ្តាលមកពីការសម្រាលកូនមិនតាមបច្ចេកទេស គ្មានអនាម័យ គ្មានសុវត្ថិភាព ឱ្យឆ្មបបូរាណធ្វើការបញ្ជូនស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យសុខភាពនៅមណ្ឌលសុខភាព និងមកសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកធ្វើការបញ្ជូនទារក កុមារ និងជនដែលងាយរងគ្រោះទៅមណ្ឌលសុខភាព និងមន្ទីរពេទ្យដែលមានសេវាសុខភាពសមស្រប ។

២- បណ្តុះបណ្តាលមេភូមិ អ្នកស្ម័គ្រចិត្តក្នុងភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក៏ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យចូលរួមក្នុងការជួយស្ត្រី និងគ្រួសារធ្វើការត្រៀមជុំវិញកំណើត (ត្រៀមលក្ខណៈជាស្រេចមុនពេលស្ត្រីឈឺពោះ សម្រាលកូន ដូចជាត្រៀមថវិកា សម្ភារៈមធ្យោបាយដឹកជញ្ជូន អ្នកកំដរ ជាដើម) និងធ្វើការបញ្ជូនស្ត្រី ឬអ្នកជម្ងឺទៅរកសេវាថែទាំព្យាបាល

៣- ស្វែងរកមូលនិធិក្នុងសហគមន៍ដើម្បីជួយក្នុងការបញ្ជូនស្ត្រី ឬអ្នកជម្ងឺដែលក្រីក្រទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក។

**គ- តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាៈ**

១-ផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋគ្រប់រូប (ស្ត្រី បុរស គ្រួសារ សមាជិកសហគមន៍) ដើម្បីបង្កើនការយល់ដឹង ស្វែងរក និងមកទទួលសេវាថែទាំ និងព្យាបាលបានទាន់ពេលវេលា។ ការផ្សព្វផ្សាយទាំងនោះធ្វើសម្រាប់ជម្ងឺឆ្លងនានា ជម្ងឺមិនឆ្លង គ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ឱសថក្លែងក្លាយព្រមទាំងសុខភាពបន្តពូជ រួមមាន ការពិនិត្យផ្ទៃពោះ ការសម្រាលកូនមានអនាម័យ មានសុវត្ថិភាព ការថែទាំក្រោយសម្រាល ការពន្យារកំណើត ការបង្ការជម្ងឺកាមរោគ ការការពារការឆ្លងមេរោគអេដស៍ជាដើម។

២-យុទ្ធនាការ ផ្តល់សេវាសុខភាព ក៏ដូចជាការអប់រំសុខភាព រួមទាំងប្រាប់ពីទីកន្លែងដែលមានសេវាទាំងនោះផង ក្នុងករណីដែលចាំបាច់។

***សំណួរទី២៨ : របាយការណ៍ ៤២,៥ភាគរយ នៃស្ត្រីរកស៊ីផ្លូវភេទ បានឆ្លងជំងឺអេដស៍នៅក្នុងឆ្នាំ១៩៩៨ (ទំព័រទី៦៦) ហើយរបាយការណ៍ក៏បានបង្ហាញផងដែរថា "ការនាំអេដស៍របស់បុរសដែលឆ្លងពីស្ត្រីរកស៊ីផ្លូវភេទទៅចម្លងដល់ភរិយារបស់ខ្លួន (ឬសង្សាររបស់ខ្លួន) និងបន្តទៅដល់កូនកំពុងតែកើនឡើង" (ទំព័រទី៦៧)។ សូមផ្តល់ព័ត៌មានអំពីកម្មវិធីជាក់លាក់ដែលមាន ដើម្បីកាត់បន្ថយអត្រានៃការរីករាលដាលនៃមេរោគហ៊ីវនៅក្នុងចំណោមក្រុមស្ត្រីដែលងាយរងគ្រោះទាំងនេះ ហើយបើសិនជាពុំទាន់មានកម្មវិធីជាក់លាក់ណាមួយនោះទេ សូមផ្តល់ព័ត៌មានថាតើ មានផែនការនឹងរៀបចំកម្មវិធីជាក់លាក់នេះទេ?***

**ចម្លើយ :**

កម្មវិធីជាក់លាក់ និងសកម្មភាពជាច្រើនបានអនុវត្តនៅទូទាំងប្រទេសដើម្បីប្រយុទ្ធនឹងការរីករាលដាលនៃមេរោគអេដស៍ :

១- អនុវត្តយុទ្ធសាស្ត្រនៃការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ នៅទូទាំងប្រទេស។

២- សេវាពិនិត្យឈាមរកមេរោគអេដស៍ដោយរក្សាការសម្ងាត់ និងមានការប្រឹក្សា និងស្ម័គ្រចិត្តត្រូវបានផ្តល់ជូនអតិថិជននៅតាមទីតាំងចំនួន ៧៨កន្លែង នៅទូទាំងប្រទេស ក្នុងនោះមាន១៥កន្លែង សហការគ្រប់គ្រងរួមជាមួយអង្គការក្រៅរដ្ឋាភិបាល។

៣- ការទប់ស្កាត់ការឆ្លងរោគពីម្តាយទៅកូនត្រូវបានពង្រីកជាបន្តបន្ទាប់។ ក្នុងនេះមានការផ្តល់ប្រឹក្សានៅពេលដែលស្ត្រីមកពិនិត្យផ្ទៃពោះ ធ្វើការពិនិត្យឈាមរកមេរោគអេដស៍ដោយរក្សាការសម្ងាត់ និងដោយស្ម័គ្រចិត្ត ផ្តល់ការប្រឹក្សាក្រោយការពិនិត្យឈាម និងក្រោយពីទទួលលទ្ធផលឈាម ផ្តល់ឱសថប្រឆាំងនឹងមេរោគអេដស៍ និងជម្ងឺឱកាសនិយមដល់ស្ត្រីមានផ្ទៃពោះមុនពេលសម្រាលនិងដល់ទារកក្រោយសម្រាលភ្លាម និងបន្តរហូតដល់អាយុ១ឆ្នាំ ផ្តល់ការគាំទ្រ តាមដាន និងថែទាំបន្តដល់អ្នកផ្ទុកមេរោគអេដស៍ដល់ផ្ទះ។

៤- ការផ្តល់ឱសថពន្យារអាយុជីវិតដល់អ្នកជម្ងឺអេដស៍។

៥- រៀបចំយុទ្ធនាការប្រឆាំងនឹងជម្ងឺអេដស៍ យ៉ាងទៀងទាត់។

ដូចនេះហើយ បានជាអត្រាប្រេវ៉ាឡង់មនុស្សពេញវ័យផ្ទុកមេរោគអេដស៍បានធ្លាក់ចុះជាលំដាប់ពី ៣,៣% នៅឆ្នាំ១៩៩៨ មកដល់ ២,៦% នៅឆ្នាំ២000 ២,១% នាឆ្នាំ២00១ និង ១,៩ % នាឆ្នាំ២00៣ ឯអត្រាប្រេវ៉ាឡង់នៃស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍បានចុះថយពី ២,៥% នៅឆ្នាំ ១៩៩៩ មកនៅ ២,១% នៅឆ្នាំ ២00៣។

## មាត្រា ១៣

**សំណួរទី២៩ : របាយការណ៍បានបង្ហាញអោយឃើញថា រាជរដ្ឋាភិបាលមានការចាប់អារម្មណ៍អំពីតម្រូវការឱ្យមានកម្មវិធីកំណែទម្រង់ដីធ្លីគ្រប់ជ្រុងជ្រោយមួយ ហើយរបាយការណ៍ក៏បានបង្ហាញថា នឹងមានការរៀបចំបង្កើតនូវគោលនយោបាយដីធ្លីគ្រប់ជ្រុងជ្រោយមួយ ដែលនឹងផ្តល់លទ្ធភាពដល់ស្ត្រីដែលជាមេគ្រួសារក្នុងការទទួលបានដីធ្លីសម្រាប់សង់ផ្ទះ និងធ្វើកសិកម្ម (ទំព័រទី៧៣)។ សូមផ្តល់ព័ត៌មានអំពីស្ថានភាពនៃគោលនយោបាយនេះ និងពន្យល់អំពី ថាតើគោលនយោបាយនេះធានាថា ស្ត្រីរួមទាំងស្ត្រីក្រីក្រ និងស្ត្រីជនជាតិភាគតិចអាចទទួលបានដីធ្លីយ៉ាងដូចម្តេច?**

**ចម្លើយ :**

ចំពោះរបាយការណ៍ថា នឹងរៀបចំបង្កើតនូវគោលនយោបាយដីធ្លី គ្រប់ជ្រុងជ្រោយមួយ ចំពោះជន ក្រីក្រខ្វះទីលំនៅ ខ្វះដីសម្រាប់ប្រកបរបរកសិកម្ម ក្នុងការទទួលបានដីសម្រាប់សង់ផ្ទះ និងធ្វើកសិកម្ម រាជរដ្ឋាភិបាលបាននឹងកំពុងពិចារណា និងធ្វើការពិគ្រោះយោបល់ជាមួយអង្គការអន្តរជាតិ មូលនិធិអន្តរជាតិតាមរយៈគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិរួចរាល់ហើយ។ ដោយឡែកចំពោះស្ត្រីក្រីក្រ និងស្ត្រីជនជាតិភាគតិចក៏អាចទទួលបាននូវផលប្រយោជន៍អំពីនយោបាយដីធ្លីនេះ ដូចជាជនក្រីក្រ ខ្វះទីលំនៅ ខ្វះដីសំរាប់ប្រកបរបរកសិកម្មដទៃទៀតផងដែរ។ ម្យ៉ាងទៀត ក្រសួងអភិវឌ្ឍន៍ជនបទកំពុងតែរៀបចំកម្មវិធីសំរាប់អភិវឌ្ឍន៍ជនជាតិភាគតិចស្របតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកំពស់

ជីវភាពរស់នៅ ដើម្បីកាត់បន្ថយភាពក្រីក្រជូនស្ត្រីក្រីក្រ និងស្ត្រីជនជាតិភាគតិចដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយដូចខាងក្រោម ៖

- ជនជាតិភាគតិចអាចប្រើប្រាស់តាមប្រពៃណីចំពោះដីដែលមានជាក់ស្តែង ដូចជាដីកសិកម្ម ដីលំនៅដ្ឋាន ដីសម្រាប់គោរពបូជា " សម្រាប់សែនអ្នកតា " ។
- ទទួលស្គាល់ដីជាកម្មសិទ្ធិសមូហភាព ក៏ដូចជាដីកម្មសិទ្ធិឯកជនផងដែរ ។
- ស្ត្រីក្រីក្រ និងជនជាតិភាគតិចមានសិទ្ធិរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់របស់ខ្លួន។
- ស្ត្រីក្រីក្រ និងស្ត្រីជនជាតិភាគតិចរស់នៅតាមសហគមន៍ ហើយទទួលបានផលប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់ ( មាត្រា ២៣ ច្បាប់ភូមិបាល) ។

**មាត្រា ១៤**

**សំណួរទី៣០ ៖ ប្រជាពលរដ្ឋ ៨៥ភាគរយ រស់នៅក្នុងតំបន់ជនបទ (ទំព័រទី៧១) ។ របាយការណ៍បាននិយាយថា ការអនុវត្តផែនការជាតិកាត់បន្ថយភាពក្រីក្រ គឺនៅទន់ខ្សោយសម្រាប់ស្ត្រីនៅជនបទដោយមានការខ្វះខាតថវិកា(ទំព័រទី៧៤) ។ សូមផ្តល់ព័ត៌មានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើង ដើម្បីបង្កើនការផ្តល់ថវិកាសម្រាប់ការអនុវត្តផែនការជាតិកាត់បន្ថយភាពក្រីក្រ និងជាពិសេសដើម្បីធានាថា ស្ត្រីនៅជនបទទទួលផលប្រយោជន៍ពីយុទ្ធសាស្ត្រនេះ ។ សូមបញ្ជាក់ផងដែរអំពីរូបភាពនៃការចូលរួមរបស់ស្ត្រីនៅជនបទ នៅក្នុងការរៀបចំ និងការអនុវត្តផែនការជាតិកាត់បន្ថយភាពក្រីក្រ?**

**ចម្លើយ ៖**

១-ការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

ក្នុងទសវត្សកន្លងមក ជនក្រីក្រកម្ពុជានៅជនបទ បានទទួលផលប្រយោជន៍តែតិចតួចប៉ុណ្ណោះពីកំណើនសេដ្ឋកិច្ចដែលមានស្ថេរភាព និងដោយសារការរីកលូតលាស់ផ្នែកឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់។ ផលប្រយោជន៍ទាំងឡាយពីការពង្រីកសេដ្ឋកិច្ចត្រូវបានប្រមូលផ្តុំនៅតាមទីក្រុងធំៗ និងក្នុងសង្គមមួយចំនួនជាហេតុធ្វើឱ្យគំលាតរវាងអ្នកមាននិងអ្នកក្រ និងរវាងទីក្រុងនិងជនបទកាន់តែរីកធំឡើង។ ទោះបីកំណើនសេដ្ឋកិច្ចដែលបានកើនឡើងជាមធ្យម ៦,៦ ភាគរយរវាងឆ្នាំ១៩៩៣ និង២០០៣ សន្ទស្សន៍ភាពក្រីក្រស្ថិតនៅខ្ពស់ និងមិនមានផ្លាស់ប្តូរច្រើនទេ ចំពោះប្រជាជនក្រីក្រនៅជនបទដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រក្នុងឆ្នាំ១៩៩៩ គឺមានប្រហែល៤០ ភាគរយ។ ក្នុងអំឡុងពេលនៃរបាយការណ៍ឆ្នាំ២០០៣ នេះ យើងកំពុងរង់ចាំលទ្ធផលនៃការវិភាគតួលេខពីការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ២០០៣-២០០៤ ដើម្បីត្រួតពិនិត្យនិន្នាការនៃភាពក្រីក្រនៅកម្ពុជាបច្ចុប្បន្ន និងពីផលប៉ះពាល់នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការកាត់បន្ថយភាពក្រីក្រ។

**២- ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីពន្លឿនការកាត់បន្ថយភាពក្រីក្រនៅជនបទ**

រាជរដ្ឋាភិបាលបានខិតខំរៀបចំ និងបានអនុម័តវិធីសាស្ត្រដែលមានដំណោះស្រាយច្រើន (multi-pronged approach) ដើម្បីពន្លឿនការអភិវឌ្ឍជនបទ និងផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីរៀបចំផែនការ និងការគ្រប់គ្រងសហគមន៍របស់ខ្លួនដោយខ្លួនឯង ។ វិមជ្ឈការ និងវិសហមជ្ឈការនៃការផ្តល់សេវាសាធារណៈ ការគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ដែលផ្អែកលើការប្រមូលផ្តុំ ការចូលរួម និងការផ្តល់ឥណទានដល់គ្រួសារ និងអាជីវកម្មខ្នាតតូចក្នុងតំបន់ជនបទ គឺជាផ្នែកមួយនៃការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។

ការអនុម័តច្បាប់ស្តីពីរដ្ឋបាលឃុំ/សង្កាត់ក្នុងឆ្នាំ២០០១ និងការបោះឆ្នោតឃុំ/សង្កាត់ ដែលបានប្រព្រឹត្តទៅនៅខែកុម្ភៈឆ្នាំ ២០០២ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងដំណើរការកម្ពុជាឆ្ពោះទៅសករាជថ្មីនៃលិទ្ធិប្រជាធិតេយ្យនៅថ្នាក់មូលដ្ឋានស្របគ្នាជាមួយការបង្កើតគណៈកម្មការជាតិសម្រាប់គាំទ្រឃុំ/សង្កាត់។ មាននារី ចំនួន ៩៨៣ រូបជាសមាជិកឃុំ/សង្កាត់ក្នុងចំណោមសមាជិកឃុំ/សង្កាត់ ១១, ២៦១ រូប ។ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល បានផ្តល់ការបណ្តុះបណ្តាលដល់នារីជាបេក្ខជន និងជាសមាជិក ឃុំ/សង្កាត់។ គណៈកម្មការផែនការ និងថវិកាឃុំ/សង្កាត់ថ្មីមានតំណាងនារីម្នាក់ និងបុរសម្នាក់ពីភូមិនីមួយៗដែលស្ថិតនៅក្រោមឃុំ/សង្កាត់នីមួយៗ ។ ក្នុងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ៤០ ភាគរយនៃសមាជិក គឺជា នារីភេទ។

**៣-ការចូលរួមរបស់ស្ត្រីជនបទក្នុងការកាត់បន្ថយភាពក្រីក្រ**

ស្ត្រីនៅជនបទបានចូលរួមក្នុង :

- ក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (CDC & VCD)
- ការរៀបចំផែនការអភិវឌ្ឍន៍ ផែនការថវិកាភូមិ ឃុំ ឬសង្កាត់ និងការតាមដានពិនិត្យ ការវាយតម្លៃការអនុវត្ត និងការងាររដ្ឋបាលទូទៅ
- ការគ្រប់គ្រងឥណទានជនបទ
- ការថែរក្សាសុខភាពក្នុងគ្រួសារ
- ការអប់រំគ្រួសារ និងកូនចៅ ។ល។

**(ភ្ជាប់ជូនតារាងស្ថិតិនៅផ្នែកខាងក្រោយ)**

## មាត្រា ១៥ និង មាត្រា ១៦

**សំណួរទី៣១ : សូមផ្តល់ព័ត៌មានបញ្ជាក់អំពីវិធានការដែលបានអនុវត្ត ដើម្បីផ្សព្វផ្សាយព័ត៌មាន និងដើម្បីធ្វើយ៉ាងណាអនុវត្តច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារប្រកបដោយប្រសិទ្ធភាពក្នុងគោលបំណងដើម្បីលុបបំបាត់ករណីរៀបអាពាហ៍ពិពាហ៍ដែលមានការរៀបចំ ។**

**ចម្លើយ ៖**

វិធានការដែលបានអនុវត្តដើម្បីផ្សព្វផ្សាយព័ត៌មាន និងធានាការអនុវត្តច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារប្រកបដោយប្រសិទ្ធភាព ដើម្បីលប់បំបាត់ករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមាន ៖

**១-ផ្សព្វផ្សាយរៀនសូត្រអំពីច្បាប់**

- ក្រសួងកិច្ចការនារី បានធ្វើការបើកវគ្គផ្សព្វផ្សាយ និងរៀនសូត្រអំពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងកិច្ចការពារផ្លូវច្បាប់ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋានខេត្ត-ក្រុង និងស្រុក-ខណ្ឌ ។

- ក្រសួងយុត្តិធម៌ បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល បើកវគ្គរៀនសូត្រដល់មន្ត្រីរាជការគ្រប់ខេត្ត-ក្រុង អំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ដែលក្នុងនេះមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារផងដែរ ។

- ទន្ទឹមនឹងនេះ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលធ្វើការពាក់ព័ន្ធនឹងស្ត្រី ក៏បានបើកវគ្គដូចគ្នានេះនៅតាមមូលដ្ឋាននានាផងដែរ ។

- រួមជាមួយនឹងការបើកវគ្គដោយផ្ទាល់ដូចបានជំរាបជូនខាងលើ ការអប់រំអំពីច្បាប់នេះក៏បានធ្វើផងដែរនៅក្នុងកម្មវិធីបញ្ច្រាបយេនឌ័រ ។

វិធានការខាងលើនេះ គឺមានគោលបំណងធ្វើឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីគោលការណ៍ និងសេរីភាពក្នុងការជ្រើសរើសគូស្រករ និងការរៀបអាពាហ៍ពិពាហ៍ ដើម្បីជំនះទៅលើផ្នត់គំនិតនៃទម្លាប់ចាស់ ។

**២-ការអប់រំណែនាំ**

ទន្ទឹមនឹងការផ្សព្វផ្សាយរៀនសូត្រអំពីច្បាប់ វិធានការមួយចំនួនទៀតក៏បានដំណើរការផងដែរ គឺការអប់រំណែនាំជាពិសេសដល់មន្ត្រីអត្រានុកូលដ្ឋានឱ្យបានយល់ដឹងអំពីគោលការណ៍នៃការជ្រើសរើស និងរៀបអាពាហ៍ពិពាហ៍នេះដែរ ដើម្បីឱ្យមន្ត្រីអត្រានុកូលដ្ឋានយកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋទប់ស្កាត់ការរៀបការដោយបង្ខំ ព្រោះមន្ត្រីទាំងនេះគឺជាអ្នកអនុញ្ញាតច្បាប់ និងចុះសំបុត្រអាពាហ៍ពិពាហ៍ ។

ក្រោយការបោះឆ្នោតឃុំ-សង្កាត់ ក្រសួងមហាផ្ទៃបានបើកវគ្គរៀនសូត្រដល់គ្រប់ក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេស អំពីរបៀបរបបធ្វើការ អំពីតួនាទីភារកិច្ច និងអំពីសមត្ថកិច្ចដែលក្នុងនេះមានតួនាទីជាមន្ត្រីអត្រានុ-កូលដ្ឋានផងដែរ ។

តាមរយៈវិធានការខាងលើ រហូតមកដល់បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងច្រើនអំពីសេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍ ។ នៅកម្ពុជា ឪពុកម្តាយមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបអាពាហ៍ពិពាហ៍កូនប្រុស ស្ត្រី ដែលមជ្ឈដ្ឋានខាងក្រៅមើលឃើញថា ការរៀបអាពាហ៍ពិពាហ៍កូនប្រុសស្រីគឺស្ថិតនៅក្នុងការឃុំគ្រងរបស់ឪពុកម្តាយទាំងស្រុង ។ ប៉ុន្តែតាមការពិត ឪពុកម្តាយមុននឹងរៀបអាពាហ៍ពិពាហ៍ឱ្យកូនជានិច្ចកាលគឺសួរចិត្តរបស់កូន (ទាំងប្រុស និងស្រី) ។ ប៉ុន្តែជាទូទៅកូនស្រីជាពិសេសនៅតាមជនបទតែងតែប្រគល់ការសម្រេចនេះឱ្យឪពុកម្តាយជាអ្នកសម្រេច ។

**សំណួរទី៣២ ៖ ដោយផ្អែកលើរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាលើស្ត្រី បានបង្ហាញអោយឃើញថា ការមានសហពន្ធ័ច្រើន គឺកើតឡើងនៅកន្លែងជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ( កថាខណ្ឌ ៩៥១ E/CN.4/2003/75/Add.1 ) ។ សូមផ្តល់ព័ត៌មានបង្ហាញពីវិធានការដែលបាននឹងកំពុងអនុវត្ត ឬបានគ្រោងហើយ ដើម្បីលុបបំបាត់ករណីមានសហពន្ធ័ច្រើន ។**

**ចម្លើយ ៖**

នៅក្នុងប្រទេសកម្ពុជា ច្បាប់រដ្ឋធម្មនុញ្ញកំណត់អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ មិនអនុញ្ញាតឱ្យបុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់បានរំលាយ រៀបការជាថ្មីបានទេ ។ ដូច្នេះនៅប្រទេសកម្ពុជា បុរស-ស្ត្រីមិនអាចមានប្រពន្ធ-ប្តីលើសពីមួយបានឡើយ ។

តាមរបាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាក្នុងគ្រួសារបានបង្ហាញថា ការមានសហព័ទ្ធច្រើន គឺកើតមាននៅកន្លែងជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការលើកឡើងបែបនេះគឺមិនសមស្របនោះទេ ។ តាមពិតអ្វីដែលកើតមាននៅកម្ពុជានោះ មិនមែនប្តីច្រើន-ប្រពន្ធច្រើននោះទេ (Polygamy) ព្រោះអ្នកទាំងនេះ មិនអាចរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់នោះឡើយ ។ កន្លងមក នៅក្នុងច្បាប់កម្ពុជាបានហាមឃាត់មិនឱ្យមានសហព័ទ្ធលើសពីមួយ ប៉ុន្តែពុំទាន់មានច្បាប់សម្រាប់ផ្តន្ទាទោសចំពោះអ្នកដែលមានសហព័ទ្ធច្រើនដែរ ។ ដូច្នេះគេអាចក្លែងបន្លំរៀបអាពាហ៍ពិពាហ៍បានដោយខុសច្បាប់ ។

ដើម្បីលុបបំបាត់ការក្លែងបន្លំនេះ នៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមានបញ្ញត្តិផ្តន្ទាទោសដល់អ្នកដែលមានសហព័ទ្ធច្រើនពីបទទ្វេពន្ធភាព ។

## ពិធីសារស្តីពីជំរើសផ្សេងៗ

**សំណួរទី៣៣ ៖ សូមផ្តល់ព័ត៌មានអំពីវិធានការ ឬសកម្មភាពដែលបានអនុវត្តដើម្បីនាំទៅរកការចុះសច្ចាប័នលើពិធីសារនេះ ។**

**ចម្លើយ ៖**

វិធានការ ឬសកម្មភាពដែលបានអនុវត្តដើម្បីនាំទៅរកការឱ្យសច្ចាប័នលើពិធីសារផ្សេងៗ គឺបន្ទាប់ពីបានទទួលពិធីសារផ្សេងៗពីអង្គការសហប្រជាជាតិមក រាជរដ្ឋាភិបាលកម្ពុជាផ្តល់ឱ្យស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធសហ-ការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើការពិនិត្យពិភាក្សាទៅលើខ្លឹមសារនៃពិធីសាររួចហើយលើកយោបល់ផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលដើម្បីសម្រេច ។

បន្ទាប់ពីសម្រេចយល់ព្រមហើយ រាជរដ្ឋាភិបាលរៀបចំឯកសារស្នើរសុំសច្ចាប័ន ស្តីពីការអនុម័តយល់ព្រមលើពិធីសារផ្សេងៗនោះពីរដ្ឋសភា និងព្រឹទ្ធសភា ។